N·46
15.12.02

# ក

## មាតិកា

### I-ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


២៨-១១-២០០២ -ព្រះរាជក្រឹត្យ នស/១១០២/៣២៥ ស្តីពីការតែងតាំងឯកឧត្តម **កែវ ចុន្ទារិន** ជាទីប្រឹក្សាសម្តេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភា ទទួលបន្ទុកការងារប្រៃសណីយ៍ និងទូរគមនាគមន៍ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ៣៤១៣

២៨-១១-២០០២ -ព្រះរាជក្រឹត្យ នស/១១០២/៣២៦ ស្តីពីការតែងតាំងឯកឧត្តម **ហុង ពីច** ជាឧកញ៉ា ៣៤១៤

២៨-១១-២០០២ -ព្រះរាជក្រឹត្យនស/១១០២/៣៣១ស្តីពីការតែងតាំងលោកជំទាវ**កែវ ម៉ាលី** ជាឧកញ៉ា ៣៤១៥

២៨-១១-២០០២ -ព្រះរាជក្រឹត្យ នស/១១០២/៣៣៤ ស្តីពីការបំពាក់គ្រឿងឥស្សរិយយសការពារជាតិជូននាយទាហានថ្នាក់ឧត្តមសេនីយ៍ ចំនួន ៣៨ រូប ក្នុងមួយរូបៗ មេដាយមាស ចំនួន ០១ គ្រឿង,មេដាយប្រាក់ ចំនួន ០១ គ្រឿង,មេដាយសំរឹទ្ធ ចំនួន ០១គ្រឿង ៣៤១៦


### II-រាជរដ្ឋាភិបាល

### ១-អនុក្រឹត្យ


១១-១២-២០០២ -អនុក្រឹត្យលេខ ១២០ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ៣៤១៩

១៣-១២-២០០២ -អនុក្រឹត្យលេខ ១២១ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ៣៤២១

០៦-១២-២០០២ -អនុក្រឹត្យលេខ ៥៦០ អនក្រ.តត ស្តីពីការតែងតាំងបម្រើរាជការ ៣៤២៣

០៩-១២-២០០២ -អនុក្រឹត្យលេខ ៥៦១ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៣៤២៤

០៩-១២-២០០២ -អនុក្រឹត្យលេខ ៥៦២អនក្រ.តត ស្តីពីការតែងតាំងផ្លាស់ប្តូរមុខងារនិងតម្លើងឋានន្តរសក្តិ ៣៤២៥

១១-១២-២០០២ -អនុក្រឹត្យលេខ ៥៦៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣៤២៦

១២-១២-២០០២ -អនុក្រឹត្យលេខ ៥៦៤ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៣៤២៧


### III-ការងារបណ្តាក្រសួង

### ១-ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ


០៩-១២-២០០២ -សារាចរណែនាំលេខ ០០៩ សហវ.ឧហ ស្តីពីការផ្តល់អាជ្ញាប័ណ្ណ ធានារ៉ាប់រង បណ្តោះអាសន្ន ៣៤២៨

១២-១២-២០០២ -ប្រកាសលេខ ៨៤៦ សហវ ស្តីពីការបំពេញបន្ថែមគណនី ក្នុងប្លង់គណនេយ្យរដ្ឋ ៣៤៣៣


### ២- ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម


១៤-១២-២០០២ -ប្រកាសលេខ ២៨៩ MoC/M 2002 ស្តីពីការដាក់ឱ្យដេញថ្លៃលើកូតា សំលៀកបំពាក់ដែលត្រូវនាំចេញទៅសហរដ្ឋអាមេរិក សំរាប់ប្រើប្រាស់ក្នុងឆ្នាំ ២០០៣ ៣៤៣៥

46.

ខ

## ៣~ ទីស្តីការរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា


| | | |
|---|---|---|
| ១១-១២-២០០២ | -ប្រកាសលេខ ៣៣៨ សកបយ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល | ៣៤៣៩ |
| ១១-១២-២០០២ | -ប្រកាសលេខ ៣៣៩ សកបយ ស្តីពីការបង្កើតគណៈកម្មការគ្រប់គ្រងពលករបរទេស | ៣៤៥៩ |

# ព្រះរាជក្រឹត្យ

នស/រកត/១១០២/៣២៥

## យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់អោយប្រើជាផ្លូវការ នូវច្បាប់រដ្ឋធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៣៤ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ១៩៩៩
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៤៣ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់តែងតាំង ប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចប្រធានព្រឹទ្ធសភា

## ត្រាស់បង្គាប់

**មាត្រា ១ :** តែងតាំងឯកឧត្តម **កែប ចុះឡិន** ជាទីប្រឹក្សាសម្តេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភា ទទួលបន្ទុកការងារប្រៃសណីយ៍ និងទូរគមនាគមន៍ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ដោយពុំទទួលប្រាក់បៀវត្ស ។

**មាត្រា ២ :** ប្រធានព្រឹទ្ធសភា និងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ

នរោត្តម សីហនុ

លេខ : ៦២៥៣ច.ល

ដើម្បីថតចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ២០០២

ករល-៦៧-១១-០០៣៤២

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

សុខ សាន់

# ព្រះរាជក្រឹត្យ

នស/រកត/១១០២/៣២៦

## យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

## តែងតាំង

ឯកឧត្តម ហួង ពីជ

ជា

## ឧកញ៉ា

ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ
នរោត្តម សីហនុ

លេខ : ២៥២ច.ល
ដើម្បីចម្លងចែក

ពរល-០៧-១១.០០៣៤៣

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ៨ ឆ្នាំ២០០២

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

សុខ ទី តាន់

# ព្រះរាជក្រឹត្យ

នស/រកត/១១០២/៣៣១

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

តែងតាំង

លោកជំទាវ កែវ ម៉ាលី

ជា

ឧកញ៉ា

ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ

នរោត្តម សីហនុ

លេខៈ ២៥១ ច.ល

ដើម្បីចម្លងចែក

ពរល.០៧.១១.០០៣៤៨

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០០២

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ ១២ ឆ្នាំ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាវី តាន់

# ព្រះរាជក្រឹត្យ

នស/រកត/១១០២/៣៣៤

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/ រកត/ ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស/ ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា ១** : បំពាក់គ្រឿងឥស្សរិយយសការពារជាតិ ជូននាយទាហានថ្នាក់ឧត្តមសេនីយ៍ ចំនួន ៣៨ រូប ក្នុងមួយរូប ៗ មេដាយមាស ចំនួន ០១ គ្រឿង , មេដាយប្រាក់ ចំនួន ០១ គ្រឿង , មេដាយសំរិទ្ធ ចំនួន ០១ គ្រឿង ដូចមានរាយនាមខាងក្រោម ៖

១-ឧត្តមសេនីយ៍ត្រី **ជឹម សុខ** អត្តលេខ ០០០៦៤៦ នាយករងទីចាត់ការបុគ្គលិក អគ្គបញ្ជាការដ្ឋាន

២-ឧត្តមសេនីយ៍ត្រី **មាស សក្តិ** អត្តលេខ ០០០៧៤៧ នាយករងអធិការកិច្ច អគ្គបញ្ជាការដ្ឋាន

៣-ឧត្តមសេនីយ៍ត្រី **ស៊្រុន សារឿន** អត្តលេខ ០០០៩៣០ មេបញ្ជាការ កងពលតូចលេខ ៣១ យោធភូមិភាគទី ៣

៤-ឧត្តមសេនីយ៍ត្រី **ច្រាក់ ផល្លី** អត្តលេខ ០០២១០៥ មេបញ្ជាការរង និងជានាយសេនាធិការ បញ្ជាការដ្ឋានរថក្រោះ

៥-ឧត្តមសេនីយ៍ត្រី **សុខ ចារុណា** អត្តលេខ ០០ ១០៩០ មេបញ្ជាការរង កងពលតូចលេខ ៧០

៦ - ឧត្តមសេនីយ៍ត្រី **ឡៅ សារុន** អត្តលេខ ០០២៣៣២ មេបញ្ជាការរង កងពលតូចលេខ ៧០

៧ - ឧត្តមសេនីយ៍ត្រី **យឹម លាង** អត្តលេខ ០០៥១៨២ មេបញ្ជាការ អង្គរក្សសម្តេចប្រធានព្រឹទ្ធសភា

៨- ឧត្តមសេនីយ៍ត្រី **នាម អឿង** អត្តលេខ ០០០៣០៧ មេបញ្ជាការរងនិងជានាយសេនាធិការយោធភូមិភាគទី ១

៩- ឧត្តមសេនីយ៍ត្រី **គីម គន្ធា** អត្តលេខ ០០២៤៦៧ នាយករងទីចាត់ការកលយុទ្ធ អគ្គបញ្ជាការដ្ឋាន

១០- ឧត្តមសេនីយ៍ត្រី **ម៉ា សាខួន** អត្តលេខ ០០០៣១៩ មេបញ្ជាការរង យោធភូមិភាគ ទី ២

១១- ឧត្តមសេនីយ៍ត្រី **សុខ យាន** អត្តលេខ ០០០៨៥៧ ទីប្រឹក្សាអគ្គមេបញ្ជាការ

១២- ឧត្តមសេនីយ៍ត្រី **ប្រាក់ ផល្លី** អត្តលេខ ០០៣២៣៧ ជំនួយការ សម្តេចនាយករដ្ឋមន្ត្រី

១៣- ឧត្តមសេនីយ៍ត្រី **ទេព្យ គីមហាន** អត្តលេខ ០០០៣៨០ ទីប្រឹក្សា ក្រសួងការពារជាតិ

១៤- ឧត្តមសេនីយ៍ត្រី **ឃួន មុយឃួន** អត្តលេខ ០០០៧១៦ នាយករងមជ្ឈមណ្ឌលស្រាវជ្រាវយុទ្ធសាស្ត្រយោធា

១៥- ឧត្តមសេនីយ៍ត្រី **យៀង គីមសួរ** អត្តលេខ ០០០៤៩៥ នាយករងខុទ្ទកាល័យអគ្គបញ្ជាការដ្ឋាន

១៦- ឧត្តមសេនីយ៍ត្រី **ពេជ្រ សុផា** អត្តលេខ ០០០៣២០ នាយករងសាលានាយទាហានចំរុះ អគ្គបញ្ជាការដ្ឋាន

១៧- ឧត្តមសេនីយ៍ត្រី **ផាន់ សាមន្ថា** អត្តលេខ ០០១១៨៨ នាយក នាយកដ្ឋានសោធននិវត្តន៍

១៨- ឧត្តមសេនីយ៍ត្រី **ឈុន សារឿន** អត្តលេខ ០០០៥៣៤ នាយករង នាយកដ្ឋានបុគ្គលិក

១៩- ឧត្តមសេនីយ៍ត្រី **មាស លី** អត្តលេខ ០០០៥៣៨ នាយករង នាយកដ្ឋានបុគ្គលិក

២០-ឧត្តមសេនីយ៍ត្រី **ចាន់ សារ៉ាង** អត្តលេខ ០០០៥២៧ នាយករងខុទ្ទកាល័យក្រសួងការពារជាតិ

២១- ឧត្តមសេនីយ៍ត្រី **គួច តិរម្យ** អត្តលេខ ០០០៥២៦ នាយករង នាយកដ្ឋាននយោបាយផែនការ

២២- ឧត្តមសេនីយ៍ត្រី **ឡេង ឡៃហ៊ាង** អត្តលេខ ០០១៤១៨ នាយករង នាយកដ្ឋាននីតិកម្ម

២៣- ឧត្តមសេនីយ៍ត្រី **ជា វាសនា** អត្តលេខ ០០៣២១០ នាយករង នាយកដ្ឋាននីតិកម្ម

២៤- ឧត្តមសេនីយ៍ត្រី **នួន សំបូរ** អត្តលេខ ០០០៥៥៦ នាយករង នាយកដ្ឋានភូមិសាស្ត្រ

២៥- ឧត្តមសេនីយ៍ត្រី **យិន សុខា** អត្តលេខ ០០១៦២០ នាយករង វិទ្យាស្ថានយោធាកម្ពុជា

២៦- ឧត្តមសេនីយ៍ត្រី **អៀង ផលលាភ** អត្តលេខ ០០០៥៦៥ នាយករង នាយកដ្ឋានហិរញ្ញវត្ថុ

២៧- ឧត្តមសេនីយ៍ត្រី **សុខ វណ្ណារ៉ា** អត្តលេខ ០០០៥៦៧ នាយករង នាយកដ្ឋានហិរញ្ញវត្ថុនិងជានាយការិយាល័យផែនការ អគ្គនាយកដ្ឋានភ័ស្តុភារ -ហិរញ្ញវត្ថុ

២៨- ឧត្តមសេនីយ៍ត្រី **ម៉ែន ចាន់នារា** អត្តលេខ ០០១៥៦៥ នាយក នាយកដ្ឋានផលិតសំភារៈយោធា អគ្គនាយកដ្ឋានសំភារៈបច្ចេកទេស

២៩- ឧត្តមសេនីយ៍ត្រី **អោម វិចិត្រ** អត្តលេខ ០០០៥៦៨ នាយករង នាយកដ្ឋានបច្ចេកទេសនិងជានាយការិយាល័យ ផែនការអគ្គនាយកដ្ឋានសំភារៈបច្ចេកទេស

៣០- ឧត្តមសេនីយ៍ត្រី **ស៊ុំ ខាំចាន់នារ៉ុង** អត្តលេខ ០០១១៦៦ នាយករង នាយកដ្ឋានពត៌មាននិងជានាយការិយាល័យ ផែនការអគ្គនាយកដ្ឋានយោធសេវា

៣១- ឧត្តមសេនីយ៍ត្រី ម៉ូ ផាន់សារី អត្តលេខ ០០០៦១៣ នាយករង នាយកដ្ឋានវិស្វកម្ម

៣២- ឧត្តមសេនីយ៍ត្រី ស៊ីម សុភាព អត្តលេខ ០០០៦០៥ នាយករង នាយកដ្ឋានអប់រំ

៣៣- ឧត្តមសេនីយ៍ត្រី នាង ផែន អត្តលេខ ០០០៦០២ នាយករង នាយកដ្ឋានអប់រំ

៣៤- ឧត្តមសេនីយ៍ត្រី ព្រហ្ម ឌីអ អត្តលេខ ០០១៦៤១ នាយករង នាយកដ្ឋានទាក់ទងអន្តរជាតិ

៣៥- ឧត្តមសេនីយ៍ត្រី អ៊ុំ សារិទ្ធ អត្តលេខ ០០០១១០០ នាយករង ទីចាត់ការចលនូបត្ថម្ភ

៣៦- ឧត្តមសេនីយ៍ត្រី សុខ សុវណ្ណា អត្តលេខ ០០០៨៣៤ ទីប្រឹក្សា អគ្គបញ្ជាការដ្ឋាន

៣៧- ឧត្តមសេនីយ៍ត្រី ជា សុវណ្ណឧត្តម អត្តលេខ ០០០៨៦២ នាយករង នាយកដ្ឋានស្រាវជ្រាវចារកិច្ច អគ្គបញ្ជាការដ្ឋាន

៣៨- ឧត្តមសេនីយ៍ត្រី ឡោក ឆាយ អត្តលេខ ០០៣៦១២ ជំនួយការ សម្តេចប្រធានព្រឹទ្ធសភា

មាត្រា ២ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ

នរោត្តម សីហនុ

លេខ ៧៤៩ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ.ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ២០០២

អគ្គលេខាធិការរាជរដ្ឋាភិបាល

សុខ តាន់

នករ.០៧.១១-០០៣៩១

ធ្វើនៅព្រះបរមរាជវាំង.រាជធានីភ្នំពេញ. ថ្ងៃទី២៨ ខែវិច្ឆិកាឆ្នាំ ២០០២

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ :..១២០...អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការផ្ទេរឥណទានថវិកា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ , ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ,ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ១១/នស/៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ , ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០១/១៥ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០២
- បានឃើញអនុក្រឹត្យ លេខ ០៣ អនក្រ.បក , ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០២ ស្តីពីការបែងចែកឥណទានថវិកាចំណាយ តាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០២
- បានឃើញអនុក្រឹត្យ លេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០២ ស្តីពីការផ្ទេរឥណទានថវិកា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**សំរេច**

**មាត្រា១:** ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកា ចំនួន ៨០០ លានរៀល ( ប្រាំបីរយលានរៀល ) ពីជំពូក ៥៣ ( ការទូទាត់បំណុល ) មកជំពូក ៥២ ( កិច្ចប្រតិបត្តិការហិរញ្ញវត្ថុ ) របស់ក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០២ ។

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ចំណាយរៀបចំដើមទុនក្នុងការរកស៊ីចូលហ៊ុនគ្នារវាងក្រុមហ៊ុន "កម្ពុជារី" ជាមួយក្រុមហ៊ុន "អាស៊ានអ៊ិនសួរេនអ៊ិនធ័រណាស្យូណាល់" ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

**បានយកសេចក្តីជំរាបជូន**

**សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**គាត ឈន់**

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១៤២១ អនក្រ.បក

# អនុក្រឹត្យ

# ស្តីពីការផ្ទេរឥណទានថវិកា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ , ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ,ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១/នស/៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ , ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០១/១៥ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០២
- បានឃើញអនុក្រឹត្យលេខ ០៣ អនក្រ.បក , ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០២ ស្តីពីការបែងចែកឥណទានថវិកាចំណាយតាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០២
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក,ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០០២ ស្តីពីការផ្ទេរឥណទានថវិកា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**សម្រេច**

**មាត្រា១:** ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកា ចំនួន ៣.០០០ លានរៀល ( បីពាន់លានរៀលគត់ ) ពីជំពូក ៤០ ( ចំណាយផ្សេងៗ ) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ៣១ ( អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ច និង វប្បធម៌ ) របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០២ ។

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយផ្ទេរក្នុងជំពូកទាំងនេះ តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើង ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ផ្ដល់ជូនក្រសួងការពារជាតិ សំរាប់ឧបត្ថម្ភគោល នយោបាយជូនយោធិនពិការ ចំនួន ៨៣៥ នាក់ ដែលបានរំសាយក្នុងជំហានទី ១ ចំនួន ១៥.០០០ នាក់ ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យ នេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៣ខែ ធ្នូ ឆ្នាំ ២០០២

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

បានយកសេចក្ដីគោរពជូន
សម្ដេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

LN

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៦០ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

*******

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១០០/១១ ចុះថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ច្បាប់បន្ថែមទៅលើច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់អគ្គសវនករនៃអាជ្ញាធរសវនកម្មជាតិ

### ស ម្រេ ច

**មាត្រា ១** : ត្រូវបានតែងតាំងលោក អ៊ុំ ស៊ុំឡុន ជាប្រធាននាយកដ្ឋានសវនកម្មទី ១ នៃអាជ្ញាធរសវនកម្មជាតិ ។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គសវនករនៃអាជ្ញាធរសវនកម្មជាតិ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ - កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ:...៥៦១...អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

&&&&&

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស /៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស /រកត /១០៩៥ /០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

## ស ម្រេ ច

**មាត្រា ១ :** ត្រូវបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **សេនា** ជូនលោក **YOKOTA ,Tsuyoshi President of Company Sun of Mr. YOKOTA , Masaomi** ដែលមានស្នាដៃ និង គុណបំណាច់ខ្ពស់ ក្នុងការទ្រទ្រង់វិស័យវប្បធម៌ នៃព្រះរាជាណាចក្រកម្ពុជា ដោយបានប្រគល់វត្ថុបុរាណ ចំនួន ៥០ មុខជូនរាជរដ្ឋាភិបាលកម្ពុជា ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ [illegible] ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និង មាត្រា២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៦៧ ,អនក្រ.បក

## អនុក្រឹត្យ

### ស្ដីពី

### ការតែងតាំងផ្លាស់ប្ដូរមុខងារ និងតម្លើងឋានន្តរសក្តិ

~~~~~~~~~~

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការបង្កើត ក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្ដីពីការកែសំរួលតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- យោងតាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

### សំរេច

**មាត្រា១ :** ត្រូវបានតែងតាំងផ្លាស់ប្ដូរមុខងារ និងតម្លើងឋានន្តរសក្តិ **ថ្នាក់វរសេនីយ៍ឯក** នាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោម ÷

១-វរសេនីយ៍ទោ **គីម សោភ័ណ្ឌ** អត្តលេខ ០០១២៣៧ មេបញ្ជាការរង វរសេនាតូចលេខ ១ អង្គរក្សកងពលតូចលេខ ៧០ អគ្គបញ្ជាការដ្ឋាន

២-វរសេនីយ៍ទោ **ម៉ិន ថូ** អត្តលេខ ០០៥០២៤ មេបញ្ជាការរង តំបន់ប្រតិបត្តិការសឹករងកោះកុង បច្ចុប្បន្នជា នាយរងការិយាល័យការពារព្រំដែន កងទ័ពជើងគោក

**មាត្រា២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ ៨ ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ២
- ឯកសារ-កាលប្បវត្តិ
~~~~~~~~~~

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ៥៦៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ព្រះមហាសុមេធាធិបតីសម្តេចព្រះសង្ឃរាជគណៈមហានិកាយនៃព្រះរាជាណាចក្រកម្ពុជា

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន ០១ គ្រឿង ប្រគេនព្រះគ្រូ **កែវ សម្បត្តិ** ចៅអធិការវត្ត ទួលអង្គក្រពើ អង្គចំប៉ាមានឫទ្ធី អង្គសិរីទ្ធមានជ័យ សង្កាត់គោករកា ខណ្ឌដង្កោ រាជធានីភ្នំពេញ ដែលបានបរិច្ចាគបច្ច័យដើម្បីជួយកសាងសមិទ្ធផលនានា និង ជួយដល់ចាស់ជរា ជនក្រីក្រ ក្មេងកំព្រា សរុបបច្ច័យចំនួន ១៤៦.៦៩៨ ដុល្លារអាមេរិក ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអភិបាលរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៥៦៤ អនក្រ.តត

## អនុក្រឹត្យ

## ស្តីពីការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញ អនុក្រឹត្យលេខ ៩៥ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០០២ ស្តីពីការបង្កើតក្រុមហ៊ុនជលផល ជាសហគ្រាសសាធារណៈ
- យោងតាមសំណើរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

## សំ រេ ច

**មាត្រា ១** : តែងតាំងលោក ឡូ ប៊ុនថា ជាប្រធានអគ្គនាយកក្រុមហ៊ុនជលផល ដែលជាសហគ្រាសសាធារណៈ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះ ហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០០៥ សហវ.ឧហ

# សារាចរណែនាំ
# ស្តីពី
# ការផ្តល់អាជ្ញាប័ណ្ណធានារ៉ាប់រងបណ្តោះអាសន្ន

សារាចរនេះត្រូវបានរៀបចំឡើង ដោយឈរលើមូលដ្ឋាននៃលិខិតបទដ្ឋាន ដូចតទៅ៖

- ព្រះរាជក្រមលេខ នស/រកម/០៧០០/០២ ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធានារ៉ាប់រង
- អនុក្រឹត្យលេខ ១០៩ អនក្រ ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០១ ណែនាំអនុវត្តច្បាប់ស្តីពី ការធានារ៉ាប់រង
- ប្រកាសលេខ ៨៦៤ សហវ ឧ.ហ ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០០១ ស្តីពីការចេញអាជ្ញាប័ណ្ណធានារ៉ាប់រងជូនក្រុមហ៊ុនធានារ៉ាប់រង និង សាខារបស់ក្រុមហ៊ុនធានារ៉ាប់រងបរទេស
- ចំណាររបស់សម្តេចនាយករដ្ឋមន្ត្រីចុះថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០០២ លើលិខិតរបស់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លេខ ៤៧០៩ សហវ ចុះថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០០២
- តាមការចាំបាច់នៃការគ្រប់គ្រងសកម្មភាពធានារ៉ាប់រងរបស់នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ

ក្នុងគោលបំណងអនុវត្តច្បាប់ អនុក្រឹត្យ និង បទប្បញ្ញត្តិផ្សេងៗ ស្តីពីការធានារ៉ាប់រងអោយមានភាពរលូន និង ស្របទៅតាមទំហំនៃទីផ្សារធានារ៉ាប់រងនៅកម្ពុជា ។ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុនឹងរៀបចំបែបបទផ្តល់អាជ្ញាប័ណ្ណធានារ៉ាប់រងបណ្តោះអាសន្នដល់ក្រុមហ៊ុន និងភ្នាក់ងារធានារ៉ាប់រង ដែលកំពុងធ្វើសកម្មភាពអាជីវកម្មធានារ៉ាប់រងនៅក្នុងព្រះរាជាណាចក្រកម្ពុជា តាមលក្ខខ័ណ្ឌដូចខាងក្រោម៖

## ១ : ការផ្តល់អាជ្ញាប័ណ្ណបណ្តោះអាសន្ន

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចផ្តល់អាជ្ញាប័ណ្ណធានារ៉ាប់រងបណ្តោះអាសន្ន ជូនក្រុមហ៊ុនធានារ៉ាប់រងអោយធ្វើអាជីវកម្មធានារ៉ាប់រងបណ្តោះអាសន្ននៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយតម្រូវអោយអ្នកទទួលអាជ្ញាប័ណ្ណបំពេញលក្ខខ័ណ្ឌដូចខាងក្រោម៖

ក- គោរពតាមច្បាប់ និងអនុក្រឹត្យស្តីពីការធានារ៉ាប់រងដែលមានជាធរមាន និង បទបញ្ញត្តិ ឬ ប្រកាសផ្សេងៗដែលដាក់ចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមដំណាក់កាលនីមួយៗ ដែលទាក់ទងនឹងទំរង់ការ មាតិកា វចនាបទ ធានារ៉ាប់រង ។

ខ- បង់ប្រាក់តម្កល់ ១០% នៃដើមទុនចុះបញ្ជីចំនួន **៧០០ ០០០ ដុល្លារ** (ប្រាំពីររយពាន់ដុល្លារអាមេរិក) ចូលក្នុងគណនីប្រាក់តម្កល់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុលេខ 0102-35.1211-T140 នៅធនាគារជាតិ នៃកម្ពុជា ។

គ- បង់ប្រាក់កម្រិតសាធនភាពចំនួន **៣ ៥០០ ០០០ ដុល្លារ** (បីលានប្រាំរយពាន់ដុល្លារ) ជា ០៥ ដំណាក់កាល (ប្រាំ) ក្នុងគណនីដោយឡែកនៅធនាគារពាណិជ្ជកម្មណាមួយដែលមានការទទួលស្គាល់ពីធនាគារជាតិ នៃកម្ពុជា:

- ឆ្នាំ ទី១ : ចំនួន ៣៥០ ០០០ ដុល្លារ (បីរយហាសិបពាន់ដុល្លារអាមេរិក)
- ឆ្នាំ ទី២ : ចំនួន ៥២៥ ០០០ ដុល្លារ (ប្រាំរយម្ភៃប្រាំពាន់ដុល្លារអាមេរិក)
- ឆ្នាំ ទី៣ : ចំនួន ៧០០ ០០០ ដុល្លារ (ប្រាំពីររយពាន់ដុល្លារអាមេរិក)
- ឆ្នាំ ទី៤ : ចំនួន ៨៧៥ ០០០ ដុល្លារ (ប្រាំបីរយចិតសិបប្រាំពាន់ដុល្លារអាមេរិក)
- ឆ្នាំ ទី៥ : ចំនួន ១ ០៥០ ០០០ ដុល្លារ (មួយលានហាសិបពាន់ដុល្លារ អាមេរិក)

ឃ- ធ្វើការធានារ៉ាប់រងបន្តទៅក្រុមហ៊ុនធានារ៉ាប់រងបន្ត "កម្ពុជា រី " ចំនួនម្ភៃភាគរយ (២០%) នៃសេវាកម្មធានារ៉ាប់រងរបស់ខ្លួន ។ ចំពោះនីតិវិធីនៃការធ្វើធានារ៉ាប់រងបន្តជាមួយ កម្ពុជា រី អ្នកទទួលអាជ្ញាប័ណ្ណត្រូវអនុវត្តតាមលក្ខខ័ណ្ឌជាក់ស្តែងដោយឡែកតាមសភាពជាក់ស្តែង ។

ង- ចំពោះប្រាក់ចំណេញ អ្នកទទួលអាជ្ញាប័ណ្ណមិនអាចបែងចែកភាគលាភទៅភាគទុនិករបស់ខ្លួនបានទេ ល្គឹកណាក្រុមហ៊ុនមិនទាន់បានបង់បង្គ្រប់ប្រាក់កំរិតសាធនភាព ចំនួន ៣ ៥០០ ០០០ ដុល្លារ (បីលានប្រាំសែន ដុល្លារអាមេរិក) ។ ដើម្បីជៀសវាងការបែងចែកប្រាក់ចំណេញតាមរបៀបមិនផ្ទាល់ ឬ តាមរូបភាពផ្សេងៗ រាល់កិច្ចព្រមព្រៀងធានារ៉ាប់រងបន្ត ឬ កិច្ចសន្យាផ្សេងៗជាមួយភាគទុនិក ឬ ជាមួយសាខារបស់ខ្លួន ត្រូវមានការត្រួតពិនិត្យពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្នុងករណីមានការសង្ស័យ ។

## ២ : **សុពលភាពអាជ្ញាប័ណ្ណ**

អាជ្ញាប័ណ្ណធានារ៉ាប់រងបណ្តោះអាសន្ននេះ មានរយៈពេល ០១ ឆ្នាំ (មួយឆ្នាំគត់) គិតចាប់តាំងពីថ្ងៃចុះហត្ថលេខាលើអាជ្ញាប័ណ្ណ ។ អ្នកទទួលអាជ្ញាប័ណ្ណ ត្រូវដាក់ពាក្យស្នើសុំបន្តអាជ្ញាប័ណ្ណឱ្យបាន ០៣ខែ (បី) មុនពេលអាជ្ញាប័ណ្ណផុតសុពលភាព ។ ការបន្តសុពលភាពអាជ្ញាប័ណ្ណជាថ្មី គឺអាស្រ័យលើការប្រតិបត្តិតាមលក្ខខ័ណ្ឌចំណុចទី ០១ នៃសារាចរនេះ ។ អ្នកទទួលអាជ្ញាប័ណ្ណ ត្រូវបង់ថ្លៃអាជ្ញាប័ណ្ណចំនួន ១០ ០០០ ០០០ (ដប់លាន រៀល) សំរាប់រយៈពេល ០១ ឆ្នាំ តាមសុពលភាពអាជ្ញាប័ណ្ណបណ្តោះអាសន្នដែលផ្តល់ជូន ។

**៣ : ភាតព្វកិច្ចបង់ចំណូលជូនរដ្ឋ**

ក-អ្នកទទួលអាជ្ញាប័ណ្ណ ត្រូវបង់ពន្ធអាករផ្សេងៗ ដូចមានចែងនៅក្នុងច្បាប់សារពើពន្ធ នៃព្រះរាជាណាចក្រកម្ពុជា ។

ខ-អ្នកទទួលអាជ្ញាប័ណ្ណ ត្រូវបង់នូវវិភាគទាន ០.៥% នៃបុព្វលាភភ៉ាប់រងដុលសំរាប់សេវានៃការផ្សព្វផ្សាយបណ្តុះបណ្តាល និងការគ្រប់គ្រងទីផ្សាររបស់រដ្ឋ ជូនការិយាល័យធានារ៉ាប់រង និង ការិយាល័យជាតិធានារ៉ាប់រង ។

**៤ : ការផាកពិន័យ**

អ្នកទទួលអាជ្ញាប័ណ្ណត្រូវបង់ចំណូលដូចមានចែងក្នុងចំណុចទី ០៣ ខាងលើ និងចំណូលផ្សេងទៀតដែលកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឱ្យបានមុនថ្ងៃទី ១០ នៃខែបន្ទាប់ ក្នុងករណីបង់ក្រោយកាលកំណត់ នឹងត្រូវទទួលការផាកពិន័យដូចមានចែងក្នុងមាត្រាទី ១២៥ ដល់មាត្រា ១៤០ នៃច្បាប់សារពើពន្ធ ទៅតាមខ្លឹមសារដូចខាងក្រោម :

- យឺតយ៉ាវ ០១ ខែ ត្រូវពិន័យ ១០% បូកការប្រាក់ ២% លើចំនួនទឹកប្រាក់មិនបានបង់ ឬចំនួនដែលបង់ខ្វះ
- យឺតយ៉ាវច្រើនខែ ត្រូវពិន័យពី ២៥% ទៅ ៥០% បូកនឹងការប្រាក់ ២% លើចំនួន ប្រាក់មិនបានបង់ ឬ ចំនួនដែលបង់ខ្វះ
- ចំពោះបុព្វលាភភ៉ាប់រងដុលដែលមិនបានប្រកាសមកក្រសួង នឹងត្រូវទទួលការផាកពិន័យ ១០ (ដប់) ដង លើចំនួនបុព្វលាភភ៉ាប់រង ដែលមិនបានប្រកាសនោះ
- ក្នុងករណីមានការយឺតយ៉ាវក្នុងការផ្តល់ស្ថិតិ និងរបាយការណ៍អាជីវកម្ម តាមកាលកំណត់ដូចមានចែងក្នុងចំណុចទី ០៥ និងទី ០៦ នៃសារាចរនេះ អ្នកទទួលអាជ្ញាប័ណ្ណត្រូវបង់ពិន័យជាទឹកប្រាក់ចំនួន ១ ០០០ ០០០ រៀល (មួយលាន រៀល) ។

**៥ : ស្ថិតិ និង របាយការណ៍អាជីវកម្មធានារ៉ាប់រង**

ក្រុមហ៊ុនត្រូវថែរក្សាទុកដាក់យ៉ាងហ្មត់ចត់ល្អ នូវឯកសារផ្សេងៗដែលទាក់ទងទៅនឹងការធ្វើអាជីវកម្មធានារ៉ាប់រង ។ ក្រុមហ៊ុនត្រូវផ្តល់នូវស្ថិតិ និង របាយការណ៍អាជីវកម្មធានារ៉ាប់រងជារៀងរាល់ខែ មកក្រសួងនៅមុនថ្ងៃទី ១៥ នៃខែបន្ទាប់ ។ ស្ថិតិ និង របាយការណ៍នេះត្រូវបញ្ជាក់ថា ជាការពិត និង ត្រឹមត្រូវដោយអ្នកតំណាងម្នាក់ ដែលអ្នកទទួលអាជ្ញាប័ណ្ណផ្តល់សិទ្ធិ ។

**៦ : របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ**

ក្នុងរយៈពេល៣ខែ ក្រោយពីការបញ្ចប់ឆ្នាំនីមួយៗ ក្រុមហ៊ុនត្រូវផ្តល់ឱ្យក្រសួងនូវរបាយការណ៍ហិរញ្ញវត្ថុនៃឆ្នាំសារពើពន្ធកន្លងទៅ ដែលត្រូវបានត្រួតពិនិត្យដោយសវនករគណនី ដែលមានការឯកភាពពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

## ៧ : ការត្រួតពិនិត្យបញ្ជី

រយៈពេល ០៧ ថ្ងៃ (ប្រាំពីរ) ក្រោយពីការជូនដំណឹងជាលាយលក្ខណ៍អក្សរ ឬ ក្នុងករណីចាំបាច់ ក្រសួងមានសិទ្ធិចុះធ្វើការត្រួតពិនិត្យបញ្ជីគណនេយ្យ និង ឯកសារផ្សេងៗទៀត ដែលពាក់ព័ន្ធទៅនឹងការធ្វើអាជីវកម្មធានារ៉ាប់រង ។ ក្រុមហ៊ុនត្រូវសហការ និង បង្កលក្ខណៈងាយស្រួលដល់មន្ត្រីរបស់ក្រសួង ដើម្បីធ្វើការត្រួតពិនិត្យបញ្ជីស្នាម និង ឯកសារផ្សេងៗ ។ ក្នុងករណីពុំមានរបាយការណ៍ហិរញ្ញវត្ថុ ក្រសួងមានសិទ្ធិជួលអ្នកឯកទេសផ្នែកគណនេយ្យ ដើម្បីចូលរួមក្នុងកិច្ចប្រតិបត្តិការត្រួតពិនិត្យ និង មានសិទ្ធិថតចម្លងនូវឯកសារផ្សេងៗ តាមតម្រូវការក្នុងការត្រួតពិនិត្យ ហើយចំពោះរាល់ការចំណាយលើអ្នកឯកទេសផ្នែកគណនេយ្យនេះ ក្រុមហ៊ុនជាអ្នកទទួលបន្ទុក ។

## ៨: ការលុបចោលអាជ្ញាប័ណ្ណ

ក្រសួងមានសិទ្ធិលុបចោលអាជ្ញាប័ណ្ណទៅតាមព្រឹត្តិការណ៍ និង ដំណោះស្រាយទាំងឡាយដែលក្រុមហ៊ុនពុំបានឆ្លើយតបក្រោយរយៈពេល ១៥ ថ្ងៃ ទៅនឹងសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សររបស់ក្រសួង ដើម្បីដោះស្រាយទៅលើការមិនគោរព និង មិនអនុវត្តតាមលក្ខខ័ណ្ឌដូចខាងក្រោម :

ក-អ្នកទទួលអាជ្ញាប័ណ្ណពុំបានអនុវត្តតាមច្បាប់ អនុក្រឹត្យ និង បទប្បញ្ញត្តិស្តីពីការធានារ៉ាប់រង ព្រមទាំងការណែនាំផ្សេងៗរបស់ក្រសួង ដែលបានធ្វើឡើងទៅតាមដំណាក់ការនីមួយៗ ។

ខ-មានការខុសគ្នាធំដុំណាមួយរវាងរបាយការណ៍ប្រចាំខែ ឬ ប្រចាំឆ្នាំ ដែលបានដាក់ជូនក្រសួង និង របាយការណ៍អធិការកិច្ច ដែលបានរៀបចំឡើងដើម្បីដាក់ជូនក្រសួងទៅដំណាច់ឆ្នាំនីមួយៗ ។

គ-អ្នកទទួលអាជ្ញាប័ណ្ណផ្ទេរ ឬលក់អាជ្ញាប័ណ្ណទៅឱ្យអ្នកផ្សេងទៀតដែលច្បាប់មិនអនុញ្ញាត ។

ឃ ករណីក្រុមហ៊ុនក្ស័យធនក្នុងការធ្វើអាជីវកម្ម ឬមានបទល្មើសអាជីវកម្មណាមួយ ក្រសួងនឹងបញ្ឈប់សកម្មភាពធ្វើអាជីវកម្ម និង ធ្វើការទូទាត់បំណុល ហើយក្រសួងនឹងចាត់តាំងអ្នកចាត់ចែងការឱ្យទទួលបន្ទុកជំនួស ឬកាន់កាប់ទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន ។

ង-ក្នុងអំឡុងឆ្នាំអាជីវកម្មនៃសុពលភាពអាជ្ញាប័ណ្ណនេះ ក្រុមហ៊ុនមិនបានបង់ចំណូល និង ពន្ធចាប់ពី ០២ ខែ (ពីរ) ជាប់គ្នា ។

ច-អ្នកទទួលអាជ្ញាប័ណ្ណបានប្រព្រឹត្តិបទឧក្រិដ្ឋ ឬ ប្រព្រឹត្តិអំពើមិនស្របច្បាប់ណាមួយ ដែលមានការបញ្ជាក់ជាលាយលក្ខណ៍អក្សរពីអាជ្ញាធរមានសមត្ថកិច្ច ។

ឆ-អ្នកទទួលអាជ្ញាប័ណ្ណបានបង្កជំលោះក្នុងន័យបន្លំសំណង ចំពោះអ្នកត្រូវបានធានារ៉ាប់រងតាមការវិនិច្ឆ័យរបស់តុលាការ ។

## ៩ : សេចក្តីជូនដំណឹង

សេចក្តីជូនដំណឹងណាមួយដែលបានចេញដោយក្រសួង និង ចេញដោយក្រុមហ៊ុន ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរទៅកាន់អ្នកតំណាងស្របច្បាប់នៃភាគីពាក់ព័ន្ធដោយ : (១) ហុចជូនដល់ដៃ (២) ឬ តាមប្រៃសណីយ៍ (៣) ឬ ទូរសារ ។ សេចក្តីជូនដំណឹងទាំងនេះ ចាត់ទុកថាបានទទួល : (១) ដោយមានបញ្ជាក់ពេលវេលានៃការទទួល ប្រសិនបើផ្តល់ឱ្យផ្ទាល់ដៃ (២) ចុះហត្ថលេខាទទួលបើជាអនុសិដ្ឋ (៣) ឬ

នៅពេលដែលបានទទួលច្បាប់ចម្លងនៃសេចក្តីជូនដំណឹងនេះ តាមទូរសារដោយសុវត្ថិភាពប្រសិនបើផ្ញើតាមទូរសារ ។

**១០ : ច្បាប់គ្រប់គ្រង-ភាសា**

អាជ្ញាប័ណ្ណត្រូវបានគ្រប់គ្រង និង កំណត់ដោយច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។ អាជ្ញាប័ណ្ណត្រូវបានធ្វើឡើងជាភាសាខ្មែរដែលជាអត្ថបទផ្លូវការនៃអាជ្ញាប័ណ្ណ ។

**១១: សុពលភាពនៃសារាចរ**

សារាចរនេះ មានសុពលភាព ចាប់តាំងពីថ្ងៃទី ១ កក្កដា ឆ្នាំ ២០០២ តទៅ ។

ទទួលបានសារាចរណែនាំនេះ អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានពន្ធដារ ប្រធានរតនាគារជាតិ នាយកដ្ឋានពាក់ពន្ធ័ ក្រោមឱវាទ អង្គភាពខេត្ត-ក្រុង និង ក្រុមហ៊ុន និងភ្នាក់ងារធានារ៉ាប់រង ដែលកំពុងធ្វើសកម្មភាពអាជីវកម្មធានារ៉ាប់រងនៅក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវអនុវត្ត និងប្រតិបត្តិតាមខ្លឹមសារនៃសារាចរនេះ អោយមានប្រសិទ្ធភាពខ្ពស់ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ [illegible] ឆ្នាំ ២០០២

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**គាត ឈន់**

**កន្លែងទទួល**

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ធនាគារជាតិនៃកម្ពុជា
- ឯកសារ- កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ ៩៤៦ សហវ

រាជធានីភ្នំពេញ ថ្ងៃទី...... ខែ...... ឆ្នាំ ២០០២

**ប្រកាស**
**ស្តីពី**
**ការបំពេញបន្ថែមគណនីក្នុងប្លង់គណនេយ្យរដ្ឋ**

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ន.ស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/រកម/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០១/នស/ ចុះថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ ១៩៩៣ដែលប្រកាស អោយប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាស អោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម /១២០១ ចុះថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០០១ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០២
- បានឃើញព្រះរាជក្រមលេខ នស/រកម /០៧០០/០២ ចុះថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ២០០២ ដែលប្រកាស អោយប្រើច្បាប់ស្តីការធានារ៉ាប់រង
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ/បក ចុះថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ញត្តិ ទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ០៤ អ.ន.ក្រ/បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិង ការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA Phone: 855-23-724 664 Fax: 855-23-427 798

- បានឃើញប្រកាសលេខ ០០៩ ប្រក.សហវ ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ១៩៩៤ ស្តីពីប្រព័ន្ធគណនីរបស់រតនាគារជាតិ
- តាមការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**សំរេច**

**ប្រការ ១** : ត្រូវបានបំពេញបន្ថែមនៅក្នុងប្រព័ន្ធគណនីនៃគណនេយ្យរដ្ឋនូវគណនីដែលមានឈ្មោះ និង លេខសំគាល់ដូចខាងក្រោមនេះ :

គណនី " តំលៃសញ្ញាបណ្ណ័រដ្ឋដែលបានតំកល់ទុកនៅរតនាគារជាតិ " លេខគណនី ៥១១ " ។

គណនីលេខ ៥១១ ប្រើប្រាស់សំរាប់កត់ត្រាតាមដាននូវតំលៃនៃសញ្ញាបណ្ណ័រដ្ឋដែលបានតំកល់ទុកនៅរតនាគារជាតិដើម្បីបំពេញលក្ខខណ្ឌធានាសកម្មភាពអាជីវកម្ម សេវាកម្មហិរញ្ញវត្ថុរបស់អង្គភាពរដ្ឋ ។

**ប្រការ ២** : ប្រព្រឹត្តិកម្មនៃគណនី :

ខ្លឹមសារនៃគណនីនេះត្រូវបានកត់ត្រា :

**ឥណពន្ធ** : កត់ត្រាតំលៃនៃសញ្ញាប័ណ្ណរដ្ឋ ដែលបានតំកល់ទុកនៅរតនាគារជាតិដើម្បីជាការធានាសកម្មភាពអាជីវកម្ម ។

**ឥណទាន** : កត់ត្រាតំលៃនៃសញ្ញាប័ណ្ណរដ្ឋដែលបានបញ្ចេញដោយលក់ ដោយអនុប្បទាន ជំរះឬបន្ថយពីការតំកល់ទុកនៅរតនាគារជាតិ ។

**សមតុល្យ** : ឥណពន្ធិកឆ្លុះបញ្ចាំងតំលៃសញ្ញាប័ណ្ណរដ្ឋដែលកំពុងតំកល់ទុកនៅរតនាគារជាតិ ។

គណនី "តំលៃនៃសញ្ញាប័ណ្ណរដ្ឋដែលបានតំកល់ទុកនៅរតនាគារជាតិ" អាចបើកជាអនុគណនីដើម្បីធ្វើការតាមដានជាលំអិតនូវតំលៃសញ្ញាប័ណ្ណរដ្ឋទៅតាមប្រភពនិមួយៗ ។

**ប្រការ ៣** : អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ ប្រធានរតនាគារជាតិ និងអង្គភាពពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះចាប់តាំងពីថ្ងៃចុះហត្ថលេខាតទៅ ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

*កន្លែងទទួល* :

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
  " ដើម្បីជូនជ្រាប "
- ដូចប្រការ ៣
  " ដើម្បីអនុវត្ត "
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**KINGDOM OF CAMBODIA**
Nation - Religion - King

**ក្រសួងពាណិជ្ជកម្ម**
**Ministry of Commerce**
No. ២៨៥ MoC / M 2002

*ភ្នំពេញ,ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ២០០២*

# ប្រកាស

## ស្តីពីការដាក់ឱ្យដេញថ្លៃលើកូតា សំលៀកបំពាក់ ដែលត្រូវនាំចេញទៅសហរដ្ឋអាមេរិក សំរាប់ប្រើប្រាស់ក្នុងឆ្នាំ២០០៣

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែតុលា ឆ្នាំ១៩៩៤ ស្តីអំពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រក្រ/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រក្រ/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៤/អនក្រ ចុះថ្ងៃទី ២២ កញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និង ប្រព្រឹត្តិទៅនៃក្រសួងពាណិជ្ជកម្ម
- យោងតាមសុពលភាពនៃការបន្ត កិច្ចព្រមព្រៀងពាណិជ្ជកម្មវាយនភ័ណ្ឌ និងផលិតផលវាយនភ័ណ្ឌធ្វើពីកប្បាស ខ្សែន សរសៃសិប្បនិម្មិតធ្វើដោយដៃមនុស្ស សរសៃរុក្ខជាតិគ្មានជាតិកប្បាស និងសរសៃល្បាយសូត្ររវាងរាជរដ្ឋាភិបាលកម្ពុជា និង រដ្ឋាភិបាលសហរដ្ឋអាមេរិក ដែលបានចុះហត្ថលេខា កាលពី ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០០១
- បានឃើញការចាំបាច់របស់ក្រសួង

## <u>សំរេច</u>

**<u>ប្រការ១</u>-** គ្រប់រោងចក្រកាត់ដេរទាំងអស់ដែលកំពុងដំណើរការ និងដែលបានចុះបញ្ជី នៅនាយកដ្ឋានប្រពន្ធអនុគ្រោះពាណិជ្ជកម្ម (នាយកដ្ឋាន GSP ) នៃក្រសួងពាណិជ្ជកម្ម មុនថ្ងៃទី

Staff's Mobile Phones: (855-12) 818883 / 881223 Facsimile: (855-23) 426396

១៩ ខែធ្នូ ឆ្នាំ២០០២ ត្រូវបានអញ្ជើញឱ្យមកដេញថ្លៃ តាមប្រភេទផ្សេងៗ នៃ Quota ទៅតាមលទ្ធភាពផលិតកម្មរបស់ខ្លួន ។

**ប្រការ២-** រោងចក្រនិមួយៗត្រូវបានអនុញ្ញាតឱ្យដេញថ្លៃ យកបរិមាណស្មើឬតិចជាង ២០ % នៃបរិមាណកូតាសរុប ដែលដាក់ឱ្យដេញថ្លៃ តាមប្រភេទនីមួយៗនៃ Quota ដូចតទៅ :

| ប្រភេទ | បរិមាណដេញថ្លៃ (DZ) | ប្រភេទ | បរិមាណដេញថ្លៃ (DZ) |
|---|---|---|---|
| ៣៣៤/៦៣៤ | ១០០,០០០ | ៣៥២/៦៥២ | ៣៧០,០០០ |
| ៣៣៥/៦៣៥ | ៣៥,០០០ | ៤៣៥ | ១០,០០០ |
| ៣៣៨/៣៣៩ | ៥៧០,០០០ | ៤៣៨ | ៣០,០០០ |
| ៣៤០/៦៤០ | ២៧០,០០០ | ៤៤៥/៤៤៦ | ៥០,០០០ |
| ៣៤៥ | ៤០,០០០ | ៦៣៨/៦៣៩ | ៣៥០,០០០ |
| ៣៤៧/៣៤៨/៦៤៧/៦៤៨ | ១,០០០,០០០ | ៦៤៥/៦៤៦ | ២០០,០០០ |

**ប្រការ៣-** ពាក្យសុំដេញថ្លៃនីមួយៗ ត្រូវភ្ជាប់មកជាមួយនូវមូលប្បទានប័ត្រដែលមានការបញ្ជាក់ពីធនាគារ **Certified Check** ដែលមានតំលៃស្មើនឹង ១០% នៃតំលៃដេញថ្លៃសរុប ។ មូលប្បទានប័ត្រនេះ ត្រូវទូទាត់ប្រាក់ជូន គណៈកម្មាធិការគ្រប់គ្រងកូតាសំរាប់នាំចេញ ( Export Quotas Management Committee " EQMC " ) ។ ការបង់ប្រាក់កក់អប្បបរមាមិនគ្រប់ចំនួន ១០% នៃតម្លៃដេញថ្លៃសរុប និងការដាក់មូលប្បទានប័ត្រដែលគ្មានការបញ្ជាក់ពីធនាគារ នឹងចាត់ទុកថាពាក្យសុំដេញថ្លៃ គ្មានប្រសិទ្ធភាព ។

ឧទាហរណ៍ រោងចក្រ A

ដេញថ្លៃ ចំនួន ២០ ០០០ ឡូ តំលៃ ៨ ដុល្លា/ឡូ = ១៦០,០០០ ដុល្លា

ទឹកប្រាក់ ដាក់ ១០ % = ១៦,០០០ ដុល្លា

**ប្រការ៤-** ការដេញថ្លៃក្នុងតំលៃខ្ពស់បំផុតតាម **Category** នឹងបានទទួលជ័យជំនះ ។ Quota នឹងត្រូវបានបែងចែកដល់អ្នកដេញថ្លៃ ដែលបានទទួលជោគជ័យរហូតដល់បរិមាណ Quota សរុប ត្រូវបានបែងចែកអស់ ។

**ប្រការ៥-** **Quota** ដែលមិនទាន់បែងចែកនឹងបន្តទុក សំរាប់ដេញថ្លៃលើកក្រោយទៀត ។

**ប្រការ៦**- ការដេញថ្លៃនឹងត្រូវគិតយកតំលៃទស្សភាគ ០,២០ សេន នៃប្រាក់ដុល្លារអាមេរិក លើសពីតំលៃគោល ឬស្មើនឹងតំលៃគោល ចំពោះ Category នីមួយៗដូចតទៅ :

| | | | |
|---|---|---|---|
| **Cat ៣៣៤/៦៣៤** | **2.00$/doz** | **Cat ៣៥២/៦៥២** | **0.40$/doz** |
| **Cat ៣៣៥/៦៣៥** | **2.00$/doz** | **Cat ៤៣៥** | **0.40$/doz** |
| **Cat ៣៣៨/៣៣៩** | **2.00$/doz** | **Cat ៤៣៨** | **1.00$/doz** |
| **Cat ៣៤០/៦៤០** | **1.00$/doz** | **Cat ៤៤៥/៤៤៦** | **0.40$/doz** |
| **Cat ៣៤៥** | **2.00$/doz** | **Cat ៦៣៨/៦៣៩** | **1.00$/doz** |
| **Cat ៣៤៧/៣៤៨/៦៤៧/៦៤៨** | **3.00$/doz** | **Cat ៦៤៥/៦៤៦** | **0.40$/doz** |

**ប្រការ៧**- ពាក្យដេញថ្លៃត្រូវដាក់ជូន ឯកឧត្តមប្រធានគណៈកម្មាធិការគ្រប់គ្រងកូតាសំរាប់នាំចេញ " EQMC " នៃក្រសួងពាណិជ្ជកម្ម ដែលមានទីតាំង នៅអគារជាន់ទី២ លេខ ២០ B មហាវិថីព្រះនរោត្តម ។ ពាក្យសុំដេញថ្លៃត្រូវដាក់ក្នុងស្រោមសំបុត្របិទជិត ភ្ជាប់ជាមួយនូវមូលប្បទានប័ត្រ ដែលមានទឹកប្រាក់ចំនួន ១០ % នៃតំលៃដេញថ្លៃសរុបដាក់ក្នុងស្រោមសំបុត្រនោះ ។

**ប្រការ ៨**- កាលបរិច្ឆេទនៃការបើកស្រោមសំបុត្រដេញថ្លៃ គឺនៅថ្ងៃទី ២០ ខែធ្នូ ឆ្នាំ ២០០២ ចាប់ពីម៉ោង ៨:០០ ព្រឹកតទៅ នៅទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម អគារលេខ ២០ អា ជាន់ទី២ មហាវិថីព្រះនរោត្តម ។

**ប្រការ ៩**- កាលបរិច្ឆេទឈប់ទទួលពាក្យដេញថ្លៃគឺនៅថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ ២០០២ វេលា ម៉ោង ៥:០០ ល្ងាច ។

**ប្រការ ១០**- លទ្ធផលនៃការដេញថ្លៃ នឹងត្រូវប្រកាសជាសាធារណៈ នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ ២០០២ តាមប្រកាសរបស់ក្រសួងពាណិជ្ជកម្ម ។

**ប្រការ ១១**- អ្នកចូលរួមដេញថ្លៃ ដែលបានទទួលជោគជ័យ នឹងអាចប្រើប្រាស់កូតាបានចាប់ពីថ្ងៃទី ០១ ខែមករា ឆ្នាំ២០០៣ បន្ទាប់ពីបានទូទាត់តំលៃដេញថ្លៃដែលនៅសល់ ៩០% រួច ។ កាលបរិច្ឆេទចុងក្រោយនៃការទូទាត់ គឺកំណត់ត្រឹមថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០០៣ ។

**ប្រការ ១២-** អ្នកដេញថ្លៃដែលបានទទួលជោគជ័យ ប៉ុន្តែខកខានមិនបានទទួលយករបស់ខ្លួន នឹងត្រូវរឹបអូសយកប្រាក់កក់ ១០% ហើយបរិមាណកូតានោះ នឹងបន្តទុកសំរាប់ដេញថ្លៃលើកក្រោយទៀត ។ ក្រសួងពាណិជ្ជកម្មរក្សាសិទ្ធិក្នុងការ មិនអនុញ្ញាតឱ្យក្រុមហ៊ុននោះចូលរួមដេញថ្លៃកូតា លើកក្រោយៗទៀតឡើយ ។

**ប្រការ ១៣-** អ្នកចូលរួមដេញថ្លៃ ដែលមិនបានទទួលជោគជ័យ នឹងត្រូវបានផ្តល់ជូនវិញនូវប្រាក់កក់ ១០%របស់ខ្លួន ចាប់ពីថ្ងៃបន្ទាប់ពីថ្ងៃដេញថ្លៃតទៅ ។

**ប្រការ ១៤-** Quota ដែលបានទទួល តាមរយៈការដេញថ្លៃនេះ ប្រើប្រាស់បានសំរាប់ឆ្នាំសារពើពន្ធ ២០០៣ តែប៉ុណ្ណោះ ។

**ប្រការ ១៥-** ការសំរេចចិត្តរបស់ EQMC នៅក្នុងការអនុវត្តការដេញថ្លៃ ជាការសំរេចចុងក្រោយ ។

**ប្រការ ១៦-** នាយកខុទ្ទកាល័យ អគ្គនាយកបច្ចេកទេស ប្រធាននាយកដ្ឋានកាំកុងត្រូល ប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ប្រធាននាយកដ្ឋានរដ្ឋបាល រាល់ផលិតករសំលៀកបំពាក់ និង សមាជិកគណកម្មាធិការគ្រប់គ្រងកូតាសំរាប់នាំចេញ ត្រូវទទួលអនុវត្តនូវប្រការនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម ប្រសិទ្ធ**

ចំលងជូនៈ

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
  " ដើម្បីជ្រាបជាពតិមាន "
- ទូរទស្សន៍ជាតិ វិទ្យុជាតិ និងសារពត៌មានជាតិ
- ដូចប្រការ១៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សភ
MOSALVY

**ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ**
**និងយុវនីតិសម្បទា**

**លេខ : ៣៣៨ សភបយ.**

រាជធានីភ្នំពេញ. ថ្ងៃទី ១១ ខែ ៥ ឆ្នាំ ២០០២

# ប្រកាស
# ស្តីពី
# ក្រុមប្រឹក្សាអាជ្ញាកណ្តាល

*****

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ១៩៩៧ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ១៩៩៩ ដែលប្រកាស អោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ/បក ចុះថ្ងៃទី០៤ ខែ តុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។

# សំរេច

## ជំពូក ១
## សមាសភាពក្រុមប្រឹក្សាអាជ្ញាកណ្តាល

**ប្រការ១:~** ប្រកាសនេះ កំណត់ការបង្កើតក្រុមប្រឹក្សាអាជ្ញាកណ្តាលមួយ ដែលមានសមាជិកយ៉ាងតិច ១៥ រូប ដោយអនុលោមតាមមាត្រា ៣១៧ នៃច្បាប់ស្តីពីការងារ ។

ក្រសួង សង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ត្រូវចេញប្រកាសតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលជារៀងរាល់ឆ្នាំ ។ ប្រកាសតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលសំរាប់អាណត្តិថ្មី ត្រូវចេញមិនអោយយឺតជាង រយៈពេល១៤ថ្ងៃ មុនពេលបញ្ចប់អាណត្តិ ។

**ប្រការ២:~** សមាជិករបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ត្រូវបានតែងតាំងសំរាប់អាណត្តិមួយឆ្នាំ ។ អាណត្តិនេះត្រូវបានបន្តរហូតដល់ពេលចេញប្រកាសតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលអាណត្តិថ្មី ។ សមាជិកនីមួយៗអាចត្រូវបានតែងតាំងសាជាថ្មី ។

**ប្រការ៣:~** សមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលមានសមាសភាពដូចតទៅ:

ក- មួយភាគបីស្នើឡើងដោយក្រសួង សង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។

ខ- មួយភាគបីស្នើឡើងដោយសមាគមនិយោជក ដែលជាសមាជិកពេញសិទ្ធិនៃគណៈកម្មការប្រឹក្សាការងារ ។

គ- មួយភាគបីស្នើឡើងដោយសហជីពកម្មករនិយោជិត (សហពន្ធ័សហជីព) ដែលជាសមាជិកពេញសិទ្ធិនៃគណៈកម្មការប្រឹក្សាការងារ ។

សមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលត្រូវបានតែងតាំងឡើង ដោយផ្អែកតាមសំណើឈ្មោះខាងលើ ។

**ប្រការ៤:~** ករណីដែលតំណាងសមាគមនិយោជកនៅក្នុងគណៈកម្មការប្រឹក្សាការងារ មិនអាចឯកភាពគ្នាលើសំណើឈ្មោះសំរាប់សមាជិកភាពក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ សមាគមនិយោជកនីមួយៗដែលមានតំណាងពេញសិទ្ធិនៅក្នុងគណៈកម្មការប្រឹក្សាការងារមានសិទ្ធិដាក់សំណើឈ្មោះក្នុងចំនួនស្មើៗគ្នា ។

**ប្រការ៥:~** ករណីដែលតំណាងសហជីពកម្មករនិយោជិត (សហពន្ធ័) នៅក្នុងគណៈកម្មការប្រឹក្សាការងារមិនអាចឯកភាពគ្នាលើសំណើឈ្មោះសំរាប់សមាជិកភាពក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ សហជីពកម្មករនិយោជិតនីមួយៗ (សហពន្ធ័) ដែលមានតំណាងពេញសិទ្ធិនៅក្នុងគណៈកម្មការប្រឹក្សាការងារមានសិទ្ធិដាក់សំណើឈ្មោះក្នុងចំនួនស្មើៗគ្នា ។

**ប្រការ៦:-** សមាជិករបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលត្រូវមានលក្ខណៈសម្បត្តិដូចតទៅ:

ក- គ្រប់សមាជិកទាំងអស់ត្រូវមាន:-

- អាយុយ៉ាងតិច២៥ឆ្នាំ
- ការទទួលស្គាល់អំពីលក្ខណៈសម្បត្តិផ្នែកសីលធម៌
- បទពិសោធន៍ពាក់ពន្ធ័នឹងការងារយ៉ាងហោចបីឆ្នាំ ។

ខ- សមាជិកដែលត្រូវបានតែងតាំងតាមប្រការ៣ ចំណុច ក ខាងលើត្រូវមាន:

- បរិញ្ញាបត្រផ្នែកច្បាប់ ឬ មានគុណសម្បត្តិផ្នែកច្បាប់ដែលប្រហាក់ប្រហែលដទៃទៀត
- ចំណេះដឹងសមរម្យអំពីច្បាប់ស្តីពីការងារ និងបទបញ្ញាផ្សេងៗទៀតសំរាប់ប្រតិបត្តិច្បាប់នេះ ។

គ- សមាជិកដែលបានតែងតាំងតាមប្រការ៣ ចំណុច ខ និងចំណុច គ ខាងលើត្រូវមាន:

- ចំណេះដឹងសមរម្យអំពីច្បាប់ស្តីពីការងារ និងបទបញ្ញាផ្សេងៗទៀតសំរាប់ប្រតិបត្តិច្បាប់នេះ ។
- បទពិសោធន៍យ៉ាងតិចមួយឆ្នាំក្នុងវិស័យការងារ ឬការដោះស្រាយវិវាទការងារ ។

**ប្រការ៧:-** បុគ្គលដែលមិនអាចត្រូវបានតែងតាំងជាសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលមានដូចតទៅ:

ក- បុគ្គលិកមន្ត្រីរាជការនៃក្រសួង សង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។

ខ- ម្ចាស់ ឬអ្នកគ្រប់គ្រងនៃសហគ្រាសណាមួយដែលជាសមាជិកនៃអង្គការនិយោជកឬអ្នកដែលកាន់តំណែងផ្លូវការរបស់អង្គការនិយោជកណាមួយ ឬ អ្នកដែលធ្លាប់កាន់កាប់តំណែងទាំងនេះក្នុងរយៈពេល ១២ ខែមុន។

គ- សមាជិកសហជីព ឬអ្នកដែលកាន់តំណែងផ្លូវការរបស់សហជីពណាមួយ ឬអ្នកដែលធ្លាប់កាន់កាប់តំណែងទាំងនេះ ក្នុងរយៈពេល ១២ ខែមុន ។

**ប្រការ៨:-** សមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលត្រូវបានទទួលការតែងតាំង ដោយមិនប្រកាន់រើសអើងដោយមូលហេតុ សញ្ជាតិ ឬ ដោយមូលហេតុផ្សេងៗ ដូចមានចែងក្នុងមាត្រា ៣១ កថាខណ្ឌ ២ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ៩:-** ទោះបីអាណត្តិរបស់សមាជិកណាម្នាក់បានចប់ហើយក៏ដោយ ក៏សមាជិករូបនោះត្រូវបន្តការងាររបស់ខ្លួននៅក្នុងក្រុមអាជ្ញាកណ្តាល ដែលខ្លួនត្រូវបានជ្រើសរើសអោយចូលកាលពីមុនពេលផុតអាណត្តិរបស់ខ្លួន

រហូត ដល់សេចក្ដីបង្គាប់អាជ្ញាកណ្ដាលត្រូវបានធ្វើឡើង ឬ ដំណើរការសំរេចសេចក្ដីនៃអាជ្ញាកណ្ដាលត្រូវបានបញ្ឈប់ ។

**ប្រការ១០:** សមាជិកណាមួយដែលទទួលមរណភាពក្នុងអាណត្តិនៃក្រុមប្រឹក្សាអាជ្ញាកណ្ដាល ឬ ក្លាយជាអសមត្ថភាព ឬ លាលែងពីក្រុមប្រឹក្សាអាជ្ញាកណ្ដាលនេះ ត្រូវជំនួសដោយសមាជិកថ្មីសំរាប់រយៈពេលដែលនៅសល់ក្នុងអាណត្តិនោះ។ សមាជិកថ្មីនោះត្រូវបានស្នើឈ្មោះដោយស្ថាប័ន ឬ អង្គការវិជ្ជាជីវៈដែលបានបញ្ជូនឈ្មោះសមាជិកដែលចាកចេញនោះ ហើយត្រូវបានតែងតាំងស្របតាមនីតិវិធីចែងក្នុងប្រកាសនេះ ។

**ប្រការ១១:** សមាជិកក្រុមប្រឹក្សាអាជ្ញាកណ្ដាល ត្រូវបំពេញមុខងារដោយឯករាជ្យទាំងស្រុង និងនៅក្នុងរង្វង់នៃអំណាចរបស់ខ្លួន ដូចដែលមានចែងក្នុងមាត្រា៣១២ នៃច្បាប់ស្ដីពីការងារ ។ គ្មានបុគ្គលណាម្នាក់ត្រូវផ្ដល់ការ ណែនាំដល់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល ឬ ដល់សមាជិកក្រុមប្រឹក្សាអាជ្ញាកណ្ដាលទាក់ទងនឹងការដោះស្រាយវិវាទឡើយ។

សមាជិកនៃក្រុមអាជ្ញាកណ្ដាលត្រូវតែមានភាពមិនលំអៀង ។

## ជំពូក ២

## សមាសភាពក្រុមអាជ្ញាកណ្ដាល

**ប្រការ១២:** វិវាទការងាររួមទាំងឡាយដែលដាក់ជូនក្រុមប្រឹក្សាអាជ្ញាកណ្ដាល ស្របតាមមាត្រា ៣០៩ កថាខ័ណ្ឌ គ នៃច្បាប់ស្ដីពីការងារ ត្រូវដោះស្រាយដោយក្រុមអាជ្ញាកណ្ដាលមួយ ដែលត្រូវបង្កើតឡើងសំរាប់តែការដោះស្រាយវិវាទនោះ ។ សេចក្ដីបង្គាប់ដែលចេញដោយក្រុមអាជ្ញាកណ្ដាលណាមួយ ត្រូវចាត់ទុកជាសេចក្ដីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល ។ ក្រុមអាជ្ញាកណ្ដាលនីមួយៗត្រូវមានសមាជិកបីរូបដែលជ្រើសចេញពីក្រុមប្រឹក្សាអាជ្ញាកណ្ដាល ដូចខាងក្រោម:-

ក- សមាជិកមួយរូបមកពីសមាសភាពដូចមានចែងក្នុងប្រការ៣ ចំណុច ខ ខាងលើ ហើយត្រូវបានជ្រើសរើសដោយសហគ្រាសដែលជាភាគីវិវាទ

ខ- សមាជិកមួយរូបមកពីសមាសភាពដូចមានចែងក្នុងប្រការ៣ ចំណុច គ ខាងលើ ហើយត្រូវបានជ្រើសរើសដោយសហជីព ឬ ក្រុមកម្មករនិយោជិតដែលជាភាគីនៃវិវាទ

គ- សមាជិកមួយរូបដែលត្រូវធ្វើជាប្រធានក្រុមអាជ្ញាកណ្ដាល និងដែលត្រូវបានជ្រើសរើសចេញពីសមាសភាពដូចមានចែងក្នុងប្រការ ៣ ចំណុច ក ខាងលើ ដោយមានការឯកភាពពីសមាជិកទាំងពីរខាងលើ ។

នៅក្នុងករណីដែលសមាជិកទាំងពីររូបនេះមិនឯកភាពគ្នាក្នុងការជ្រើសរើសសមាជិកទីបីនៃ

ក្រុមអាជ្ញាកណ្តាល ការជ្រើសរើសនេះត្រូវធ្វើតាមការចាប់ឆ្នោតក្នុងចំណោមសមាសភាពដូច មានចែងក្នុងប្រការ ៣ ចំណុច ក ។

**ប្រការ១៣ៈ-** ក្នុងករណីដែលសហគ្រាសពីរ ឬ ច្រើនជាភាគីនៃវិវាទ ហើយពួកគេមិនអាចឈានទៅដល់ការព្រមព្រៀង ក្នុងការជ្រើសរើសសមាជិកណាមួយ សមាជិកនេះនឹងត្រូវជ្រើសរើសដោយការចាប់ឆ្នោត ។ ដូចគ្នានឹង នេះដែរ ក្នុងករណីដែលសហជីព ឬក្រុមកម្មករនិយោជិតពីរ ឬច្រើនជាភាគីវិវាទ ហើយគេមិនមានការ ឯកភាពគ្នាក្នុងការជ្រើសរើសសមាជិកណាម្នាក់នោះ សមាជិកមួយនោះនឹងត្រូវជ្រើសរើសតាមការចាប់ ឆ្នោត ។

**ប្រការ១៤ៈ-** ក្នុងករណីដែលកម្មករនិយោជិតណាម្នាក់ ត្រូវបានគេតំរូវអោយចូលរួមក្នុងសវនាការជំនុំជំរះរបស់ក្រុម អាជ្ញាកណ្តាលក្នុងពេលម៉ោងធ្វើការ និយោជករបស់កម្មករនិយោជិតនោះត្រូវតែអនុញ្ញាតអោយកម្មករ និយោជិតនោះចូលរួមដោយមិនអោយទទួលផលប៉ះពាល់ជាអវិជ្ជមានដល់សិទ្ធិការងារទាំងឡាយ ដែល កម្មករនិយោជិតនោះមានឡើយ ។

**ប្រការ១៥ៈ-** សមាជិកម្នាក់ៗនៃក្រុមអាជ្ញាកណ្តាលត្រូវបដិសេធខ្លួនឯងពីក្រុមអាជ្ញាកណ្តាលដែលខ្លួនត្រូវបានគេជ្រើស រើសប្រសិនកាលៈទេសៈដែលកើតមានឡើងចោទជាមន្ទិលសង្ស័យសមស្របអំពីភាពមិនលំអៀង ឬ ឯករាជ្យភាពរបស់ខ្លួន រួមមានទំនាក់ទំនងជិតស្និទ្ធជាលក្ខណៈបុគ្គល ឬអាជីពជាមួយសមាជិកដទៃទៀត នៃក្រុមអាជ្ញាកណ្តាល ឬជាមួយភាគីណាមួយ ឬដោយបានផលប្រយោជន៍ផ្ទាល់ខ្លួន ឬផលប្រយោជន៍ រាជីពផ្ទាល់ពីលទ្ធផលនៃរឿងក្តីនោះ ។

**ប្រការ១៦ៈ-** ការដែលសមាជិកនៃក្រុមអាជ្ញាកណ្តាលណា ដែលពុំបដិសេធខ្លួនឯងតាមបទបញ្ញត្តិដែលមានចែងក្នុង ប្រការ ១៥ ខាងលើ អាចត្រូវបានយកធ្វើជាហេតុផលសំរាប់អនុវត្តបញ្ញត្តិដែលមានចែងក្នុងប្រការ ៤៧ នៃប្រកាសនេះ ដែលទាក់ទងនឹងការពុំទទួលស្គាល់សេចក្តីបង្គាប់ ។

**ប្រការ១៧ៈ-** ក្នុងករណីដែលសមាជិកណាម្នាក់ក្នុងក្រុមអាជ្ញាកណ្តាល មិនអាចបំពេញមុខងាររបស់ខ្លួនបានដោយសារ ហេតុផលស្របច្បាប់ ឬដោយហេតុផលជាក់ស្តែងណាមួយ ត្រូវជ្រើសរើសអាជ្ញាកណ្តាលថ្មីមកជំនួស ដោយផ្អែកតាមប្រការ ១២ និង ១៣ ខាងលើ ។

## ជំពូក ៣
## ដំណើរការអាជ្ញាកណ្តាល

**ប្រការ១៨:-** ក្រុមអាជ្ញាកណ្តាល ត្រូវអញ្ជើញភាគីវិវាទមកបកស្រាយបង្ហាញដោយផ្ទាល់មាត់នូវការអះអាងរបស់ខ្លួន នៅចំពោះមុខក្រុមអាជ្ញាកណ្តាល និងដាក់ជូននូវឯកសារ និងពត៌មានចាំបាច់ផ្សេងៗទៀត ។

**ប្រការ១៩:-** ភាគីវិវាទអាចមកបង្ហាញខ្លួន នៅចំពោះមុខក្រុមអាជ្ញាកណ្តាលដោយផ្ទាល់ខ្លួន ឬដោយមានអ្នកអម ឬតំណាងដោយមេធាវីដែលជាសមាជិកនៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ឬដោយបុគ្គលផ្សេងទៀត ដែលបានទទួលការអនុញ្ញាតជាលាយល័ក្ខអក្សរពីភាគីនោះ ។

**ប្រការ២០:-** ក្នុងអំឡុងពេលនៃដំណើរការរបស់ក្រុមអាជ្ញាកណ្តាល ភាគីវិវាទទាំងឡាយត្រូវផ្អាករាល់វិធានការវិវាទ ដូចជា កូដកម្ម ឬឡុកអៅ ( ដូចមានចែងក្នុងមាត្រា ៣១៨ នៃច្បាប់ស្តីពីការងារ ) ឬវិធានការដទៃទៀត ដែលអាចធ្វើអោយស្ថានភាពវិវាទកាន់តែធ្ងន់ធ្ងរ ។ ភាគីទាំងនេះត្រូវតែចូលរួមគ្រប់កិច្ចប្រជុំទាំងឡាយដែលក្រុមអាជ្ញាកណ្តាលបានអញ្ជើញអោយចូលរួម ។

**ប្រការ២១:-** ក្នុងករណីភាគីណាមួយបានទទួលការអញ្ជើញត្រឹមត្រូវហើយ តែបែរជាខកខានមិនបានមកបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាលដោយគ្មានបង្ហាញមូលហេតុត្រឹមត្រូវ ក្រុមអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួនក្នុងពេលដែលភាគីនោះអវត្តមាន ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាលដោយចេញជាសេចក្តីបង្គាប់ ។

**ប្រការ២២:-** ទីស្នាក់ការនៃក្រុមប្រឹក្សាអាជ្ញាកណ្តាលគឺនៅភ្នំពេញ ។ តែទោះជាយ៉ាងណាក៏ដោយក្រុមអាជ្ញាកណ្តាលអាចជួបប្រជុំនៅកន្លែងណាផ្សេងទៀតក៏បាន នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលខ្លួនគិតថា សមរម្យសំរាប់ពិគ្រោះយោបល់នៅក្នុងចំណោមសមាជិករបស់ខ្លួន សំរាប់ជួបជាមួយភាគី សាក្សី ឬអ្នកជំនាញការសំរាប់ត្រួតពិនិត្យវត្ថុ ទ្រព្យសម្បត្តិដទៃទៀត ឬឯកសារ ឬការចុះពិនិត្យដល់ទីកន្លែងផ្ទាល់ ។ នៅក្នុងករណីបែបនេះក្រុមអាជ្ញាកណ្តាលត្រូវជូនដំណឹងដល់ភាគីពាក់ព័ន្ធអំពីទីកន្លែងថ្មី ដែលបានជ្រើសរើសសំរាប់សកម្មភាពរបស់ខ្លួននេះ ។

**ប្រការ២៣:-** ភាសាដែលត្រូវប្រើក្នុងដំណើរការរបស់ក្រុមអាជ្ញាកណ្តាល គឺភាសាខ្មែរ ។

**ប្រការ២៤:-** ក្រុមអាជ្ញាកណ្តាលមានអំណាចក្នុងការស៊ើបពត៌មានអំពីស្ថានភាពសេដ្ឋកិច្ចនៃសហគ្រាស និងស្ថានភាពសង្គមនៃកម្មករនិយោជិត ដែលពាក់ព័ន្ធនៅក្នុងវិវាទ ។ក្រុមនេះអាចដឹកនាំការស៊ើបអង្កេតណាមួយដែលមានការទាក់ទងនឹងសហគ្រាស ឬអង្គការវិជ្ជាជីវៈផ្សេងៗ ព្រមទាំងអាចតម្រូវអោយភាគីប្រគល់ជូននូវឯកសារ ឬពត៌មានខាងសេដ្ឋកិច្ច គណនេយ្យ ស្ថិតិ ហិរញ្ញវត្ថុ ឬរដ្ឋបាលដែលអាចមានប្រយោជន៍ក្នុងការបំពេញបេសកកម្មរបស់ខ្លួន ។ ក្រុមអាជ្ញាកណ្តាលនេះអាចសុំអោយអ្នកជំនាញការជួយបានទៀតផង ។

**ប្រការ២៥៖** ក្រុមអាជ្ញាកណ្តាល ត្រូវមានសេរីភាពក្នុងការកំណត់អំពីភាពដែលអាចទទួលយកបានភាពពាក់ពន្ធ័ភាពសំខាន់ និងទំងន់នៃភស្តុតាង និងមានសេរីភាពក្នុងការកំណត់អោយភាគីណាមួយលើកភស្តុតាងមកបញ្ជាក់ទៀតផង ។

**ប្រការ២៦៖** ក្រុមអាជ្ញាកណ្តាលមានអំណាចក្នុងការសាកសួរសាក្សី បើសិនជាយល់ឃើញថាសមស្រប ។ ក្រុមអាជ្ញាកណ្តាលត្រូវកំណត់អំពីថ្ងៃ ពេលវេលា និងទីកន្លែងសំរាប់សាកសួរសាក្សី ។ ភាគីវិវាទទាំងអស់មានសិទ្ធិក្នុងការសាកសួរសាក្សី នៅចំពោះមុខក្រុមអាជ្ញាកណ្តាល ។

**ប្រការ២៧៖** គ្រប់សេចក្តីថ្លែង ឯកសារ ឬពតិមានផ្សេងទៀតដែលប្រគល់ជូនក្រុមអាជ្ញាកណ្តាលដោយភាគីមួយត្រូវតែបញ្ជូនទៅភាគីមួយទៀត ។ ទន្ទឹមនឹងនេះដែរ គ្រប់របាយការណ៍របស់អ្នកជំនាញការ ឬឯកសារភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយោងដើម្បីធ្វើសេចក្តីសំរេច ត្រូវតែបញ្ជូនទៅភាគីវិវាទផងដែរ ។ ក្រុមអាជ្ញាកណ្តាលមានអំណាចក្នុងការចេញសេចក្តីសំរេចសមស្រប ដើម្បីការពារដល់ភាពអាថិកំបាំងនៃពតិមាននេះ ។

**ប្រការ២៨៖** លើកលែងករណីដូចមានចែងក្នុងប្រការ ២៧ ខាងលើ សមាជិកទាំងអស់នៃក្រុមអាជ្ញាកណ្តាលត្រូវតែរក្សាជាអាថិកំបាំងនូវរាល់ពតិមាន និងឯកសារដែលខ្លួនបានទទួលព្រមទាំងអង្គហេតុណាមួយដែលខ្លួនបានដឹងក្នុងពេលបំពេញភារកិច្ច ។

**ប្រការ២៩៖** ការប្រជុំទាំងឡាយរបស់ក្រុមអាជ្ញាកណ្តាលត្រូវធ្វើឡើងជាសម្ងាត់ ។

**ប្រការ៣០៖** ក្រុមអាជ្ញាកណ្តាលអាចអញ្ជើញភាគីវិវាទទាំងអស់ជាលើកចុងក្រោយ ដើម្បីជួយអោយពួកគេឈានទៅដល់ដំណោះស្រាយមួយ ។ ប្រការនេះមិនអាចនាំអោយមានការពន្យាពេលហួសពីរយៈពេលកំណត់ដែលមានចែងក្នុងមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារឡើយ លើកលែងតែភាគីទាំងពីរព្រមព្រៀងចំពោះការពន្យាពេលនោះ ។ ការព្រមព្រៀងគ្នារវាងភាគីវិវាទក្នុងអំឡុងពេលនៃដំណើរការ ក្រុមអាជ្ញាកណ្តាលអាចធ្វើជាកម្មវត្ថុនៃសេចក្តីបង្គាប់អាជ្ញាកណ្តាលបាន ។

**ប្រការ៣១៖** ដំណើរការរបស់អាជ្ញាកណ្តាល ត្រូវអនុវត្តតាមវិធាននៃនីតិវិធីរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលជាឧបសម្ព័ន្ធនៃប្រកាសនេះ ។

## ជំពូក ៤
## អំណាចយុត្តាធិការ និង សំណង

**ប្រការ៣២៖** ក្រុមអាជ្ញាកណ្តាលត្រូវសំរេចសេចក្តី លើវិវាទការងាររួមដែលដាក់មកខ្លួន ដោយយោងទៅតាមមាត្រា ៣០៩ កថាខ័ណ្ឌ គ នៃច្បាប់ស្តីពីការងារ ។

**ប្រការ៣៣:**-អំណាចរបស់ក្រុមអាជ្ញាកណ្តាលក្នុងការពិចារណាទៅលើវិវាទមួយ ត្រូវកំរិតត្រឹមតែបញ្ហាទាំងឡាយណាដែលមានក្នុងកំណត់ហេតុនៃការផ្សះផ្សាមិនបានសះជា រួមទាំងបញ្ហាជាផលវិបាកផ្ទាល់នៃវិវាទនោះដែលកើតឡើងក្រោយការធ្វើកំណត់ហេតុ ។

**ប្រការ៣៤:**-ចំពោះបញ្ហាដែលបានដាក់ជូនក្រុមអាជ្ញាកណ្តាល ក្រុមនេះមានសិទ្ធ និងអំណាចក្នុងការសំរេចអោយភាគីវិវាទផ្តល់សំណងយ៉ាងពេញលេញចំពោះរាល់ការបំពានបទបញ្ញត្តិ ដែលមាននៅក្នុងច្បាប់ស្តីពីការងារ បទបញ្ញត្តិអនុវត្តច្បាប់ស្តីពីការងារ អនុសញ្ញារួម ឬក្នុងកាតព្វកិច្ចផ្សេងទៀត ដែលកើតចេញពីទំនាក់ទំនងវិជ្ជាជីវៈរវាងនិយោជក និងកម្មករនិយោជិត ។ ក្នុងដែនអនុវត្តនៃច្បាប់ស្តីពីការងារ និងប្រកាសនេះ ក្រុមអាជ្ញាកណ្តាលមានសិទ្ធិ និងអំណាចក្នុងការសំរេចអោយភាគីវិវាទផ្តល់នូវសំណងរដ្ឋប្បវេណី ឬសំណងខូចខាតដែលមានលក្ខណៈត្រឹមត្រូវ និងយុត្តិធម៌ដោយ រួមទាំងការៈ-

ក- បញ្ជាអោយទទួលយកកម្មករនិយោជិតដែលបានបណ្តេញចេញអោយចូលមកធ្វើការវិញ នៅក្នុងតំណែងចាស់ ឬតំណែងសមរម្យណាមួយ

ខ- បញ្ជាអោយបង់ប្រាក់ជាបន្ទាន់នូវប្រាក់ដែលត្រូវបង់

គ- បញ្ជាអោយបញ្ឈប់ជាបន្ទាន់នូវកូដកម្ម ឬឡុកអៅដែលកំពុងធ្វើឡើងដោយភាគីវិវាទ

ឃ- បញ្ជាអោយបញ្ឈប់ជាបន្ទាន់នូវរាល់ការប្រព្រឹត្តទាំងឡាយណា ដែលមិនស្របច្បាប់ ឬដែលត្រូវហាមឃាត់ ដោយរួមទាំងអំពើសងសឹក និងអំពើផ្សេងៗទៀតក្រៅពីអំពើសងសឹក

ង- បញ្ជាអោយធ្វើការចរចា

ច- បញ្ជាអោយអនុវត្តតាមដំណោះស្រាយក្រោមប្រការ ៣០ នៃប្រកាសនេះ

ឆ- បង្កើតលក្ខខណ្ឌទាំងឡាយសំរាប់អនុសញ្ញារួម

ជ- សងការខូចខាតផ្សេងៗទៀតតាមការសមស្រប ។

**ប្រការ៣៥:**-ក្រុមប្រឹក្សាអាជ្ញាកណ្តាល អាចជូនដំណឹងអំពីសេចក្តីបង្គាប់របស់ខ្លួនទៅនាយកដ្ឋានអធិការកិច្ចការងារ ឬមន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទាខេត្ត-ក្រុង ដើម្បីជួយចាត់វិធានការក្នុងការអនុវត្តន៍សេចក្តីបង្គាប់នោះ ។

## ជំពូក ៥
## សេចក្តីបង្គាប់អាជ្ញាកណ្តាល

**ប្រការ៣៦:**-ក្រុមអាជ្ញាកណ្តាល ត្រូវព្យាយាមអោយបានសម្លេងឯកច្ឆន្ទក្នុងការសំរេចសេចក្តីរបស់ខ្លួន ។ ប្រសិនបើសម្លេងឯកច្ឆន្ទមិនអាចរកបានទេក្រុមអាជ្ញាកណ្តាលត្រូវធ្វើសេចក្តីសំរេចរបស់ខ្លួនតាមសម្លេងភាគច្រើន ។

**ប្រការ៣៧:**-ក្រុមអាជ្ញាកណ្ដាលត្រូវកត់ត្រារាល់សេចក្ដីសំរេចរបស់ខ្លួន ក្នុងសេចក្ដីបង្គាប់មួយដែលត្រូវចុះហត្ថលេខារបស់អាជ្ញាកណ្ដាលទាំង ០៣ រូប ។ ក្នុងករណីដែលអាជ្ញាកណ្ដាលណាម្នាក់មិនឯកភាពនឹងសេចក្ដីសំរេចតាមមតិភាគច្រើននោះ គាត់អាចកត់ត្រាយោបល់ជំទាស់របស់គាត់ធ្វើជាឧបសម្ព័ន្ធមួយក្នុងសេចក្ដីបង្គាប់នោះ ។

**ប្រការ៣៨:**-សេចក្ដីបង្គាប់អាជ្ញាកណ្ដាលត្រូវចែងអំពី:-

ក- ឈ្មោះរបស់អាជ្ញាកណ្ដាលទាំង ០៣ រូប

ខ- ឈ្មោះ អាសយដ្ឋាន និងទីកន្លែងធ្វើការ ឬកន្លែងស្នាក់នៅពិតប្រាកដរបស់ភាគី

គ- សេចក្ដីសង្ខេបស្ដីពីនីតិវិធី

ឃ-សេចក្ដីពិពណ៌នាអំពីបណ្ដឹង និងបណ្ដឹងតប ប្រសិនជាមាន

ង- ហេតុផលនៃការសំរេចដែលចែងនៅក្នុងសេចក្ដីបង្គាប់ ព្រមទាំងសេចក្ដីយោងទៅនឹងបញ្ញត្តិពាក់ព័ន្ធទាំងឡាយដែលមានចែងក្នុងច្បាប់ស្ដីពីការងារ បទបញ្ញត្តិសំរាប់អនុវត្តច្បាប់ស្ដីពីការងារឬអនុសញ្ញារួម ឬកិច្ចសន្យាការងារនីមួយៗ បើសិនជាមាន

ច- រាល់សេចក្ដីសំរេចរបស់ក្រុមអាជ្ញាកណ្ដាល

ឆ- កាលបរិច្ឆេទនៃការធ្វើសេចក្ដីរង្គាប់ ។

**ប្រការ៣៩:**-ក្នុងរយៈពេល ១៥ ថ្ងៃប្រតិទិន ចាប់ពីថ្ងៃដែលខ្លួនបានទទួលសំណុំរឿង ក្រុមអាជ្ញាកណ្ដាលត្រូវរាយការណ៍អំពីសេចក្ដីបង្គាប់របស់ខ្លួនជាលាយល័ក្ខអក្សរជូនទៅរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ហើយរដ្ឋមន្ត្រីចាត់ការផ្ដល់ដំណឹងទៅភាគីវិវាទភ្លាមអំពីសេចក្ដីបង្គាប់នោះដោយផ្ដល់ជូនភាគីទាំងនោះ នូវច្បាប់ចម្លងសេចក្ដីបង្គាប់ដែលបានបញ្ជាក់ថាត្រឹមត្រូវចំនួន ០១ ច្បាប់ម្នាក់ ។

**ប្រការ៤០:**-ភាគីនីមួយៗអាចជំទាស់ទៅនឹងសេចក្ដីបង្គាប់អាជ្ញាកណ្ដាល ដោយជូនពត៌មានទៅរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងយុវនីតិសម្បទា តាមសំបុត្រអនុសិដ្ឋ ឬ តាមមធ្យោបាយដែលទុកជាបានការ ក្នុងរយៈពេល ៨ ថ្ងៃប្រតិទិនបន្ទាប់ពីបានទទួលដំណឹង ។ ប្រសិនបើភាគីណាមួយនៃវិវាទបានដាក់ពាក្យជំទាស់របស់ខ្លួនក្នុងអំឡុងពេលនេះ សេចក្ដីបង្គាប់នោះមិនអាចអនុវត្តបានឡើយ ។ ក្នុងករណីនេះ បើវិវាទជាវិវាទអំពីសិទ្ធិដែលពាក់ព័ន្ធនឹងការអនុវត្តន៍បទ បញ្ញត្តិនៃច្បាប់ (ឧទាហរណ៍:បញ្ញត្តិណាមួយនៅក្នុងច្បាប់ស្ដីពីការងារ អនុសញ្ញារួម ឬសេចក្ដីបង្គាប់អាជ្ញាកណ្ដាលដែលជំនួសអនុសញ្ញារួម) ភាគីវិវាទអាច ប្ដឹងពីករណីនេះទៅតុលាការមានសមត្ថកិច្ចសំរាប់ការដោះស្រាយចុងក្រោយ ។

**ប្រការ៤១:-** សេចក្ដីបង្គាប់អាជ្ញាកណ្ដាលត្រូវក្លាយជាស្ថាពរ ហើយភាគីវិវាទមានកាតព្វកិច្ចត្រូវអនុវត្តតាមប្រសិនបើមិនមានភាគីវិវាទណាមួយដាក់ពាក្យជំទាស់ក្នុងរយៈពេល៨ថ្ងៃប្រតិទិនទេ ។

**ប្រការ៤២:-** ប្រការ ៤០ នៃប្រកាសនេះមិនអាចយកមកអនុវត្តបានទេ ក្នុងករណីដែលភាគីទាំងឡាយនៃវិវាទបានឯកភាពគ្នាជាលាយល័ក្ខអក្សរមុនពេលជូនដំណឹងអំពីសេចក្ដីបង្គាប់អាជ្ញាកណ្ដាល ឬក្នុងករណីដែលភាគីវិវាទបានជាប់កាតព្វកិច្ចអនុវត្តតាមអនុសញ្ញារួម ដែលចែងអំពីការមិនជំទាស់ទៅនឹងសេចក្ដីបង្គាប់អាជ្ញាកណ្ដាលណាមួយ ។ ក្នុងករណីនេះសេចក្ដីបង្គាប់អាជ្ញាកណ្ដាលត្រូវក្លាយជាស្ថាពរ ហើយត្រូវ យកមកអនុវត្តភ្លាមបន្ទាប់ពីការជូនដំណឹង ។

## ជំពូក ៦
## សេចក្ដីបង្គាប់ទាក់ទងនឹងវិវាទផលប្រយោជន៍

**ប្រការ៤៣:-** សេចក្ដីបង្គាប់អាជ្ញាកណ្ដាលដែលដោះស្រាយវិវាទផលប្រយោជន៍ និងដែលមកជំនួសអនុសញ្ញារួម ត្រូវមានប្រសិទ្ធភាពអនុវត្តរយៈពេលមួយឆ្នាំ ចាប់តាំងពីថ្ងៃដែលសេចក្ដីបង្គាប់ក្លាយជាស្ថាពរ លើកលែងតែភាគីវិវាទបានព្រមព្រៀងគ្នាលើការធ្វើអនុសញ្ញារួមថ្មីមួយ ដើម្បីដាក់ជំនួសសេចក្ដីបង្គាប់នោះ ។

**ប្រការ៤៤:-** សេចក្ដីបង្គាប់នេះនៅតែមានប្រសិទ្ធិភាពអនុវត្តដដែល បន្ទាប់ពីរយៈពេល១ឆ្នាំនេះ បើភាគីណាមួយមិនបានជូនដំណឹង ៣ខែមុនទៅភាគីម្ខាងទៀតថាខ្លួនមិនចង់អនុវត្តតាមសេចក្ដីបង្គាប់នោះទៀតទេ ។

**ប្រការ៤៥:-** នៅពេលដែលសេចក្ដីបង្គាប់អាជ្ញាកណ្ដាល ដែលជំនួសអនុសញ្ញារួមក្លាយជាស្ថាពរ សេចក្ដីបង្គាប់នេះត្រូវរក្សាទុកជាឯកសារ និងចុះបញ្ជីកស្របទៅតាមនីតិវិធីស្ដីពីអនុសញ្ញារួម ។

## ជំពូក ៧
## ការអនុវត្តន៍

**ប្រការ៤៦:-** ប្រសិនបើរយៈពេលជំទាស់បានផុត ហើយភាគីមួយបដិសេធការអនុវត្តន៍តាមសេចក្ដីបង្គាប់ភាគីម្ខាងទៀតអាចស្នើឱ្យតុលាការមានសមត្ថកិច្ចទទួលស្គាល់ និងអនុវត្តសេចក្ដីបង្គាប់នោះបាន ។ ភាគី ដែលបានស្នើសុំអោយទទួលស្គាល់ និងដែលស្នើសុំអោយមានការអនុវត្តន៍សេចក្ដីបង្គាប់ ត្រូវផ្ដល់ជូនតុលាការនូវសេចក្ដីបង្គាប់ច្បាប់ចំលងដែលបានបញ្ជាក់ថាត្រឹមត្រូវចំនួន១ច្បាប់ ។

**ប្រការ៤៧:-** ភាគីមួយអាចជៀសវាងការទទួលស្គាល់និងការដាក់ឱ្យអនុវត្តសេចក្ដីបង្គាប់ជាស្ថាពរនិងដែលចងកាតព្វកិច្ចតែក្នុងករណីភាគីនោះ ផ្ដល់ជូនតុលាការនូវភស្តុតាងបញ្ជាក់ថា សេចក្ដីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាលមិនមានភាពត្រឹមត្រូវ ដោយសារ :

ក- ភាគីវិវាទនោះមិនបានចូលរួមត្រឹមត្រូវក្នុងការជ្រើសរើសអាជ្ញាកណ្ដាល ឬមិនបានទទួលនូវការជូនដំណឹងត្រឹមត្រូវអំពីដំណើរការអាជ្ញា កណ្ដាល ឬត្រូវបានរារាំងយ៉ាងអយុត្តិធម៌មិនអោយធ្វើការបកស្រាយអោយបានក្បោះក្បាយអំពីរឿងក្ដីរបស់ខ្លួន ។

ខ- ការមិនអនុវត្តន៍តាមនីតិវិធីដូចមានចែងក្នុងច្បាប់ស្ដីពីការងារ ឬប្រកាសនេះ ទាក់ទងនឹងការចេញសេចក្ដីបង្គាប់ ។

គ- ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានចេញសេចក្ដីបង្គាប់ដែលហួសពីអំណាចដែលច្បាប់ស្ដីពីការងារនិងប្រកាសនេះប្រគល់អោយ ។

## ជំពូក ៨
## លេខាធិការដ្ឋាន និង ការចំណាយ

**ប្រការ៤៨:-** នាយកដ្ឋានអធិការកិច្ចការងារនៃក្រសួងសង្គមកិច្ច ការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ត្រូវទទួលបន្ទុកលើការរៀបចំ និងការប្រព្រឹត្តទៅ នៃលេខាធិការដ្ឋានរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល ។

**ប្រការ៤៩:-** ក្នុងករណីដែលអាជ្ញាកណ្ដាល មិនអាចនិយាយភាសាខ្មែរ ស្ថាប័ន ឬអង្គការវិជ្ជាជីវៈដែលស្នើឈ្មោះអាជ្ញាកណ្ដាលរូបនោះ ជាអ្នកទទួលខុសត្រូវចំពោះការចំណាយសមស្របទៅលើការបកប្រែឯកសារ និងបកប្រែផ្ទាល់មាត់ ។

## ជំពូក ៩
## ការទូទាត់ "ថ្ងៃ"

**ប្រការ៥០:-** ចំពោះចំនួនថ្ងៃដែលមានចែងក្នុងប្រការទាំងឡាយនៃប្រកាសនេះ បើថ្ងៃចុងក្រោយចំលើថ្ងៃសៅរ៍ ថ្ងៃអាទិត្យ ឬថ្ងៃដែលស្ថាប័នរដ្ឋបិទទ្វារជាផ្លូវការ រយៈពេលនោះត្រូវពន្យាបន្ថែមទៅថ្ងៃធ្វើការបន្ទាប់ ។

## ជំពូក ១០
## អន្តរបញ្ញត្តិ

**ប្រការ៥១:-** ក្នុងរយៈពេលអន្តរកាល ក្នុងអាណត្តិទី១ និង២ នៃក្រុមប្រឹក្សាអាជ្ញាកណ្ដាល រាល់សមាជិកទាំងអស់នៃក្រុមប្រឹក្សាអាជ្ញាកណ្ដាល ត្រូវបានតែងតាំងដោយក្រសួងសង្គមកិច្ច ការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ផ្អែកតាមសំណើឈ្មោះនៃក្រសួងសង្គមកិច្ច ការងារ បណ្ដុះបណ្ដាលវិជ្ជាជីវៈ និងយុវនីតិសម្បទា បន្ទាប់ពីមានការប្រឹក្សាយោបល់ជាមួយគំរោងដោះស្រាយវិវាទការងារ នៃអង្គការពលកម្មអន្តរជាតិ (ILO) ។ /១០

## ជំពូក ១១

## ការចូលជាធរមាន

<u>**ប្រការ៥២:**</u>~ ប្រកាសនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

<u>**ចម្លងជូន**</u>

--ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ទីស្តីការគណៈរដ្ឋមន្ត្រី

-គ្រប់ក្រសួងពាក់ព័ន្ធ " ដើម្បីជូនជ្រាប "

-អគ្គនាយកដ្ឋាន ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

" ដើម្បីផ្សព្វផ្សាយ និងអនុវត្ត "

-គ្រប់មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ

និងយុវនីតិសម្បទា ខេត្ត-ក្រុង "ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"

-សមាគមនិយោជក " ដើម្បីអនុវត្ត "

-សហព័ន្ធសហជីព " ដើម្បីអនុវត្ត "

-គ្រប់បណ្តាញវិទ្យុ និងទូរទស្សន៍ "ដើម្បីជួយផ្សព្វផ្សាយ "

-រាជកិច្ច

-កាលប្បវត្តិ និងឯកសារ

ឧបសម្ព័ន្ធនៃប្រកាស

លេខ ..............................

ចុះថ្ងៃទី ...........................

# វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល
# យោងតាមប្រការ ៣១ នៃប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល

## ***វិធាន ១ : លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល***

១.១ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល (លេខាធិការដ្ឋាន) ជាអង្គការ ដែលត្រូវបានបង្កើតឡើង យោងតាមជំពូក ៨ នៃប្រកាសលេខ ................. (ប្រកាស) ដើម្បីគ្រប់គ្រង និង សម្របសម្រួលដល់ការដោះស្រាយវិវាទដោយក្រុមប្រឹក្សាអាជ្ញាកណ្តាល ។

១.២ អាស័យដ្ឋានលេខាធិការដ្ឋាន គឺ :

លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល
នាយកដ្ឋានអធិការកិច្ច ក.ប.ង.ប
អគារលេខ ២៨ វិថីសម្តេចព្រះធម្មលិខិត អ៊ុក (វិថី ១៨៤)
សង្កាត់ជ័យជំនះ
ខ័ណ្ឌដូនពេញ
ភ្នំពេញ ៕

១.៣ ភាគីវិវាទដែលដាក់បណ្តឹងមកក្រុមប្រឹក្សាអាជ្ញាកណ្តាល ត្រូវសហប្រតិបត្តិការជាមួយលេខាធិការដ្ឋាន ដើម្បីជួយលេខាធិការដ្ឋានក្នុងការបំពេញមុខងាររបស់ខ្លួន និងត្រូវដោះស្រាយអោយបានឆាប់រហ័ស និង ប្រកបដោយស្ថាបនានូវសំណូមពរណាមួយ ដែលលេខាធិការដ្ឋានបានស្នើសុំឱ្យភាគីវិវាទជួយ ។

១.៤ សមាជិកក្រុមអាជ្ញាកណ្តាល និង ភាគីត្រូវប្រាស្រ័យទាក់ទងគ្នាដោយផ្ទាល់បាន តែក្នុងកំឡុងពេលជំនុំជំរះផ្លូវការនៃក្រុមអាជ្ញាកណ្តាលប៉ុណ្ណោះ ។ រាល់ការប្រាស្រ័យទាក់ទងគ្នា រវាងក្រុមអាជ្ញាកណ្តាល និង ភាគី ក្រៅពីពេលជំនុំជំរះ ត្រូវប្រព្រឹត្តទៅតាមរយៈលេខាធិការដ្ឋាន ។ លេខាធិការដ្ឋានត្រូវចាត់វិធានការសមរម្យគ្រប់បែបយ៉ាង ដើម្បីឱ្យធានាថា ការប្រាស្រ័យទាក់ទងទាំងនេះ បានទៅដល់គោលដៅ ។

១.៥ លេខាធិការដ្ឋាន ត្រូវមានវត្តមានក្នុងការជួយភាគីដែលមានសំណួរពាក់ព័ន្ធនឹងទិដ្ឋភាពនៃនីតិវិធីដោះស្រាយវិវាទ និងជួយក្នុងការបំភ្លឺបញ្ហាដែលកើតចេញពីប្រកាស ឬ ពីវិធាននៃនីតិវិធីនេះ ។

**វិធាន ២ : ការចាប់ផ្តើមអាជ្ញាកណ្តាល**

២.១ កាលណា ការដោះស្រាយវិវាទតាមអាជ្ញាកណ្តាលត្រូវបានគេតំរូវឱ្យមានតាមមាត្រា ៣០៩ (គ) នៃច្បាប់ស្តីពីការងារ ក្នុងរយៈពេល ៤៨ម៉ោងបន្ទាប់ពីការបញ្ចប់ការផ្សះផ្សាមិនសះជា ភាគីនីមួយៗត្រូវជូនយោបល់ទៅលេខាធិការដ្ឋានអំពីអាជ្ញាកណ្តាលដែលខ្លួនបានជ្រើសរើសពីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីធ្វើជាសមាជិកនៃក្រុមអាជ្ញាកណ្តាល ដែលបង្កើតឡើង ផ្អែកតាមប្រការ ១២ នៃប្រកាស ។

២.២ ក្នុងការបំពេញតាមល័ក្ខខ័ណ្ឌតម្រូវនៃវិធាន ២.១ ភាគីអាចជូនយោបល់អ្នកផ្សះផ្សា នៅពេលបញ្ចប់ការការផ្សះផ្សាមិនសះជា អំពីអាជ្ញាកណ្តាលដែលខ្លួនបានជ្រើសរើស ។ នៅពេលដែលភាគីបានជូនយោបល់អ្នកផ្សះផ្សាអំពីអាជ្ញាកណ្តាល ដែលខ្លួនបានជ្រើសរើសសម្រាប់ធ្វើសមាជិកក្រុមអាជ្ញាកណ្តាល ការជ្រើសរើសអាជ្ញាកណ្តាលនេះត្រូវបញ្ចូលទៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា ហើយបញ្ជូនឱ្យរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា យោងតាមមាត្រា ៣០៨ នៃច្បាប់ស្តីពីការងារ ។

២.៣ ភាគីដែលពាក់ព័ន្ធដំណើរការអាជ្ញាកណ្តាល ត្រូវធ្វើធានាថា លេខាធិការដ្ឋាន បានទទួលនូវការជូនដំណឹងអំពីអាស័យដ្ឋានរបស់ខ្លួន ដែលជាទីកន្លែងដែលភាគីទទួលសេចក្តីជូនដំណឹង និង សេវាផ្តល់ជូនឯកសារផ្សេងៗ ក្នុងដំណើរការជំនុំជំរះ ហើយ បើជាអាចទៅរួច ប្រគល់លេខទូរស័ព្ទដែលអាចទាក់ទង ។ ពត៌មានដូចនេះ ត្រូវប្រគល់ឱ្យ ក្នុងឱកាសមុនដំបូងបង្អស់ ហើយបើអាចទៅរួច ត្រូវប្រគល់ឱ្យទៅអ្នកផ្សះផ្សា នៅពេលបញ្ចប់ការផ្សះផ្សាមិនសះជា ។

**វិធាន ៣ : ការជ្រើសរើសអាជ្ញាកណ្តាល**

៣.១ លេខាធិការដ្ឋាន ត្រូវខ្នះខ្នែង ដើម្បីអោយអាជ្ញាកណ្តាលទាំងបី បង្កើតជាក្រុមអាជ្ញាកណ្តាលមួយ ដែលត្រូវបានជ្រើសរើសឡើង ក្នុងរយៈពេលបីថ្ងៃប្រតិទិន បន្ទាប់ពីលេខាធិការដ្ឋានបានទទួលរបាយការណ៍ផ្សះផ្សាមិនសះជា ។ លេខាធិការដ្ឋាន ត្រូវប្រើគ្រប់វិធានការដើម្បីសម្របសម្រួលដល់ការជ្រើសរើសអាជ្ញាកណ្តាលអោយបានស្របតាមវិធាននេះ ។

៣.២ កាលណាលេខាធិការដ្ឋានទទួលរបាយការណ៍ផ្សះផ្សាមិនសះជា យោងតាមមាត្រា ៣០៨ នៃច្បាប់ស្តីពីការងារ លេខាធិការដ្ឋានត្រូវចុះលេខរៀងសំណុំរឿងនៃវិវាទភ្លាមៗ ហើយពិនិត្យមើលថាតើ ភាគីបានជ្រើសរើសអាជ្ញាកណ្តាលស្របតាមប្រការ ១២នៃប្រកាសហើយឬនៅ ។

៣.៣ ប្រសិនបើភាគីមិនបានជ្រើសរើសអាជ្ញាកណ្តាល ឬអាជ្ញាកណ្តាលដែលត្រូវបានជ្រើសរើសហើយ មិនអាចបំពេញមុខងាររបស់ខ្លួនបាន ពេលនោះលេខាធិការដ្ឋានត្រូវជួយធានាអោយបានថា ភាគីទាំងអស់បានជ្រើសរើសអាជ្ញាកណ្តាល ស្របតាមជំពូក ២ នៃប្រកាស ។

៣.៤ ក្នុងការជួយដល់ដំណើរការជ្រើសរើស ស្របតាមវិធាន ៣.៣ លេខាធិការដ្ឋានត្រូវ :

(ក) ផ្តល់ឱ្យសហគ្រាសដែលជាភាគីវិវាទនូវបញ្ជីនៃអាជ្ញាកណ្តាលដែលត្រូវស្នើឈ្មោះឡើងដោយនិយោជក ក្នុងក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្របតាមប្រការ ៣ខ នៃប្រកាស ដែលការជ្រើសរើសអាជ្ញាកណ្តាលនេះ ត្រូវផ្អែកតាមប្រការនេះ ។

(ខ) ផ្តល់ឱ្យសហជីព ឬ ក្រុមកម្មករនិយោជិកដែលជាភាគីវិវាទនូវបញ្ជីនៃអាជ្ញាកណ្តាលដែលត្រូវស្នើឈ្មោះឡើងដោយសហ ជីព ក្នុងក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្រមតាមប្រការ ៣គ នៃប្រកាស ដែលការជ្រើសរើសអាជ្ញាកណ្តាលនេះ ត្រូវផ្អែកតាមប្រការនេះ ។

(ខ) ធ្វើការជ្រើសរើសអាជ្ញាកណ្តាល ដោយការចាប់ឆ្នោត កាលណាមានការតម្រូវ ក្រោមប្រការ ១៣ នៃប្រកាសនេះ ។

៣.៥ បន្ទាប់ពីបានជ្រើសរើសអាជ្ញាកណ្តាលពីបញ្ជីដូចមានចែងក្នុងប្រការ ៣ខ និង ៣គ នៃប្រកាស ("អាជ្ញាកណ្តាល២រូប") លេខាធិការដ្ឋាន ត្រូវធ្វើការទាក់ទងជាមួយអាជ្ញាកណ្តាលទាំង២រូបនោះ ដើម្បីសួរបញ្ជាក់អំពីភាពដែលគេអាចធ្វើជាអាជ្ញាកណ្តាលបាន ។ លេខាធិការដ្ឋាន ត្រូវជូនដំណឹងទៅអាជ្ញាកណ្តាលទាំង២រូបនោះ អំពីលេខរៀងសំណុំរឿង និង អំពីភាគីវិវាទ ។ អាជ្ញាកណ្តាលទាំង២ ត្រូវជូនដំណឹងទៅលេខាធិការដ្ឋាន បើសិនជាគេមិនអាចធ្វើជាអាជ្ញាកណ្តាលបាន ដោយសារមូលហេតុណាមួយ រួមទាំងមូលហេតុនៃវិសមាសភាព ដូចជាទំនាស់ផលប្រយោជន៍ជាដើម ។

៣.៦ នៅពេលអាជ្ញាកណ្តាលណាមួយដែលត្រូវបានគេជ្រើសរើស មិនអាចបំពេញមុខងារក្នុងក្រុមអាជ្ញាកណ្តាលបាន លេខាធិការដ្ឋាន ត្រូវតំរូវអោយភាគីដែលបានជ្រើសរើសអាជ្ញាកណ្តាលនោះ ធ្វើការជ្រើសរើសអាជ្ញាកណ្តាលផ្សេង ដោយយោងតាមវិធាននេះ ។

៣.៧ នៅពេលការជ្រើសរើសអាជ្ញាកណ្តាលទាំង២នោះ ត្រូវបានធ្វើរួចរាល់ហើយ អាជ្ញាកណ្តាលទាំង២ ត្រូវពិភាក្សាគ្នាដើម្បីជ្រើសរើសអាជ្ញាកណ្តាល១រូបទៀត ចេញពីបញ្ជីអាជ្ញាកណ្តាលដែលតែងតាំងដោយក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា ដូចមានចែងក្នុងប្រការ ៣ក នៃប្រកាសនេះ ("អាជ្ញាកណ្តាលទី៣") ។

៣.៨ បើសិនជាអាជ្ញាកណ្តាលទាំង២ អាចឯកភាពគ្នាលើការជ្រើសរើសអាជ្ញាកណ្តាលទី៣ អាជ្ញាកណ្តាលទាំង២ ត្រូវធ្វើការទាក់ទងជាមួយអាជ្ញាកណ្តាលទី៣ ដើម្បីសួរបញ្ជាក់អំពីភាពដែលគេអាចធ្វើជាអាជ្ញាកណ្តាលបាន ។

អាជ្ញាកណ្តាលទាំង២ ត្រូវជូនដំណឹងទៅអាជ្ញាកណ្តាលទី៣ អំពីលេខរៀងសំណុំរឿង និង អំពីភាគីវិវាទ ។ អាជ្ញាកណ្តាលទី៣ ត្រូវជូនដំណឹងទៅអាជ្ញាកណ្តាលទាំង២ បើសិនជាគេមិនអាចធ្វើជាអាជ្ញាកណ្តាលបាន ដោយសារមូលហេតុណាមួយ រួមទាំងមូលហេតុនីត្យានុកូលភាព ដូចជាទំនាស់ផលប្រយោជន៍ជាដើម ។

៣.៩ នៅពេលការជ្រើសរើសអាជ្ញាកណ្តាលទី៣នោះ ត្រូវបានធ្វើរួចរាល់ហើយ អាជ្ញាកណ្តាលទី៣ ត្រូវជូនដំណឹងអំពីសមាសភាពនៃក្រុមអាជ្ញាកណ្តាល ទៅលេខាធិការដ្ឋាន ដោយរួមទាំងលេខរៀងសំណុំរឿង ភាគីវិវាទ និង កាលបរិច្ឆេទ ពេលវេលា ដែលអាជ្ញាកណ្តាលទី៣បានបញ្ជាក់ប្រាប់អំពីភាពដែលគេអាចធ្វើជាសមាជិកក្រុមអាជ្ញាកណ្តាលនោះ ។ លេខាធិការដ្ឋានត្រូវកត់ត្រាទុកនូវពតិមានលំអិតទាំងនេះ ហើយចងក្រងទុកអោយបានសមស្រប ។

៣.១០ កាលណាមានការតំរូវដូចមានចែងក្នុងប្រការ ១២គ នៃប្រកាស ទាក់ទងនឹងការដែលអាជ្ញាកណ្តាលទាំង២មិនអាចឯកភាពគ្នាលើអត្តសញ្ញាណនៃអាជ្ញាកណ្តាលទី៣ លេខាធិការដ្ឋានត្រូវធ្វើការជ្រើសរើសអាជ្ញាកណ្តាលទី៣ ដោយការចាប់ឆ្នោត ។ ក្នុងករណីនេះ លេខាធិការដ្ឋាន ត្រូវទទួលខុសត្រូវ លើការសួរបញ្ជាក់អំពីភាពអាចធ្វើជាអាជ្ញាកណ្តាលរបស់អាជ្ញាកណ្តាលទី៣ ។

៣.១១ កាលណាមានការតំរូវអោយមាននីតិវិធីសំរាប់ការជ្រើសរើសដោយការចាប់ឆ្នោត ដោយផ្អែកតាមប្រកាស និង ដរាបណាភាគីទាំងអស់ មិនមានការព្រមព្រៀងគ្នា លើនីតិវិធីចាប់ឆ្នោតផ្សេងពីនេះទេនោះ នីតិវិធីចាប់ឆ្នោត ត្រូវអនុវត្តតាមដូចខាងក្រោម :

(ក) មន្ត្រីនៃលេខាធិការដ្ឋានម្នាក់ដែលត្រូវបានចាត់តាំងឡើង ត្រូវសរសេរលើក្រដាសសន្លឹកផ្សេង១គ្នា នូវឈ្មោះរបស់អាជ្ញាកណ្តាលនិមួយ១ពីបញ្ជីដែលពាក់ព័ន្ធ ដូចមានចែងក្នុងប្រការ ៣ក, ៣ខ, ឬ ៣គ នៃប្រកាស ។ បន្ទាប់មកទៀត មន្ត្រីនោះ ត្រូវប្រមូលក្រដាស់ទាំងនេះ ដាក់ក្នុងប្រអប់ស្រអាប់មួយ ហើយជ្រើសក្រដាស១សន្លឹក ដោយព្រៀវ ដើម្បីរើសយកអាជ្ញាកណ្តាលម្នាក់ ។

(ខ) ភាគីវិវាទ និង អាជ្ញាកណ្តាលណាមួយ ដែលត្រូវបានគេជ្រើសរើសអោយធ្វើជាសមាជិកក្រុមអាជ្ញាកណ្តាល នឹងទទួលបាននូវសេចក្តីជូនដំណឹងអំពីការប្រព្រឹត្តទៅនៃនីតិវិធីចាប់ឆ្នោត និងមានសិទ្ធិមានវត្តមានក្នុងពេលប្រព្រឹត្តទៅនៃនីតិវិធីនោះ ។

៣.១២ ក្នុងគោលបំណងនៃវិធាននេះ ការជ្រើសរើសអាជ្ញាកណ្តាលណាមួយគឺចប់រួចរាល់ នៅពេលដែលអាជ្ញាកណ្តាល ត្រូវបានគេជ្រើសរើសឡើង ដោយផ្អែកតាមនីតិវិធីកំណត់ ហើយ អាជ្ញាកណ្តាលបានបញ្ជាក់អំពីភាពដែលគាត់អាចធ្វើជាសមាជិកនៃក្រុមអាជ្ញាកណ្តាលសំរាប់វិវាទណាមួយនោះ ។

៣.១៣ កាលណាការជ្រើសរើសអាជ្ញាកណ្តាលទាំង៣ ត្រូវបានធ្វើចប់រួចរាល់ហើយ ក្រុមអាជ្ញាកណ្តាល ត្រូវបានគេចាត់ទុកថាត្រូវបានបង្កើតឡើង ។ ក្នុងពេលទន្ទឹមនឹងនេះដែរ រយៈពេល១៥ថ្ងៃប្រតិទិន ដូចមានចែងក្នុងប្រការ ៣៩ នៃ ប្រកាស ចាប់ផ្តើមរាប់ ដែលក្នុងរយៈពេលនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាល ត្រូវរាយការណ៍អំពីសេចក្តីបង្គាប់របស់ខ្លួន ។

៣.១៤ បន្ទាប់ពីក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើង កាលណាសមាជិកក្រុមអាជ្ញាកណ្តាលនេះ មិនអាចបំពេញមុខងាររបស់ខ្លួនបាន ដោយសារមូលហេតុច្បាប់ ឬមូលហេតុជាក់ស្តែង លេខាធិការដ្ឋានត្រូវធានាអោយមានការជ្រើសរើសអាជ្ញាកណ្តាលថ្មីមកជំនួស ដោយផ្អែកតាមប្រការ ១៧ នៃប្រកាស ស្របតាមនីតិវិធីតែមួយ ដូចនីតិវិធីដែលបានចែងក្នុងវិធាននេះ ។

## វិធាន ៤ : ដំណើរការអាជ្ញាកណ្តាល

៤.១ សមាជិកក្រុមអាជ្ញាកណ្តាល ត្រូវជួបប្រជុំក្នុងរយៈ៣ថ្ងៃប្រតិទិន បន្ទាប់ពីក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើង ។ ការប្រជុំនេះ អាចធ្វើតាមរយៈទូរស័ព្ទ ។ ក្រុមអាជ្ញាកណ្តាល ត្រូវជូនដំណឹងទៅលេខាធិការដ្ឋានអំពីការប្រជុំនេះ និង អំពីសេចក្តីសំរេចផ្សេងៗ ដែលបានធ្វើក្នុងពេលប្រជុំ ។ បន្ទាប់ពីបានទទួលការណែនាំពីក្រុមអាជ្ញាកណ្តាល លេខាធិការដ្ឋានត្រូវជូនដំណឹងទៅភាគីអំពីកាលបរិច្ឆេទ និង ទីកន្លែង ដែលភាគីត្រូវមកបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល ។

៤.២ ក្រៅពីការឡើងបង្ហាញដោយផ្ទាល់មាត់ ដូចមានចែងក្នុងប្រការ ១៨ នៃប្រកាស ក្រុមអាជ្ញាកណ្តាល អាចតំរូវអោយភាគីបញ្ជាក់អំពីការទាមទារ និងចំលើយរបស់ខ្លួនជាលាយល័ក្ខអក្សរ ។

៤.៣ គឺជាការស្ថិតក្នុងដែនអំណាច និង សមត្ថកិច្ចទាំងស្រុងរបស់ក្រុមអាជ្ញាកណ្តាល ក្នុងការសំរេចលើបញ្ហាផ្សេងៗ ដែលទាក់ទងនឹងការរៀបចំវិវាទអោយបានសមស្របសំរាប់ការជំនុំជំរះ និង ដែលទាក់ទងនឹងទិដ្ឋភាពណាមួយនៃការជំនុំជំរះ ។

៤.៤ ប្រធាននៃក្រុមអាជ្ញាកណ្តាល ត្រូវចំលងទុកនូវរាល់សេចក្តីណែនាំ ការជូនដំណឹង យោបល់ ឬ ការប្រាស្រ័យទាក់ដែលមានលក្ខណៈប្រហាក់ប្រហែល ដែលធ្វើឡើងដោយក្រុមអាជ្ញាកណ្តាល ក្នុងពេលជំនុំជំរះ ហើយ ត្រូវផ្តល់អោយលេខាធិការដ្ឋាននូវឯកសារទាំងនេះចំនួន១ច្បាប់ ។

៤.៥ ក្រុមអាជ្ញាកណ្តាល អាចតំរូវអោយភាគីមួយ ផ្តល់ភស្តុតាង តាមរយៈសាក្សី វត្ថុតាង ឬ ឯកសារផ្សេងៗ ។ បន្ថែមពីនេះទៀត ក្រុមអាជ្ញាកណ្តាល អាចអញ្ជើញអ្នកឯកទេស មកផ្តល់ភស្តុតាងទាក់ទងនឹងវិវាទ ។

៨.៦ ភាគីទាំងអស់ មានសិទ្ធិពិនិត្យភស្តុតាងណាមួយ ដែលបានបង្ហាញដល់ក្រុមអាជ្ញាកណ្តាល និង ចោទសួរសាក្សីណាមួយ ដែលផ្តល់ភស្តុតាងដល់ក្រុមអាជ្ញាកណ្តាល ។

៨.៧ ប្រសិនបើភាគីណាមួយ មិនបានបង្ហាញខ្លួន ឬ មិនមានអ្នកតំណាង ក្នុងដំណើរការអាជ្ញាកណ្តាល ក្រុមអាជ្ញាកណ្តាល អាចបន្តដំណើរការរបស់ខ្លួន ក្នុងអវត្តមានរបស់ភាគីនោះ ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាល ដោយចេញជាសេចក្តីបង្គាប់។ ក្នុងករណីណាមួយ ក្រុមអាជ្ញាកណ្តាល ត្រូវតែបំពេញតាមល័ក្ខខ័ណ្ឌថា ភាគីវិវាទបានទទួលការជូនដំណឹងយ៉ាងត្រឹមត្រូវ អំពីកាលបរិច្ឆេទ ពេលវេលា និង ទីកន្លែងនៃដំណើរអាជ្ញាកណ្តាល មុនពេលធ្វើសេចក្តីសំរេចរបស់ខ្លួន ។

៨.៨ ក្នុងការធ្វើសេចក្តីសំរេចទាក់ទងនឹងដំណើរការ រួមទាំងវិវាទលើនីតិវិធី ក្រុមអាជ្ញាកណ្តាល ត្រូវផ្អែកលើ ការពិចារណាលើភាពយុត្តិធម៌ ដំណោះស្រាយវិវាទប្រកបដោយប្រសិទ្ធិភាព និង តំរូវការក្នុងការដោះស្រាយវិវាទអោយបានលឿន។

៨.៩ ការផ្អាកការជំនុំជំរះអាជ្ញាកណ្តាល ធ្វើអោយខាតបង់ថវិកាច្រើន និងគួរអោយជៀសវាង ។ ការផ្អាក នឹងធ្វើទៅបានដោយក្រុមអាជ្ញាកណ្តាល កាលណាភាគីទាំងអស់ក្នុងដំណើរការអាជ្ញាកណ្តាល ឯកភាពគ្នាលើការផ្អាកនេះ។

៨.១០ ការដោះស្រាយតាមរយៈការផ្សះផ្សា ជានិច្ចកាល ជាជំរើសគួរអោយចង់បាន ហើយភាគី មានសិទ្ធិ ក្នុងការដោះស្រាយវិវាទដោយខ្លួនឯង គ្រប់ពេលវេលា រួមទាំងក្នុងពេលដំណើរការអាជ្ញាកណ្តាលផងដែរ ។

៨.១១ ក្រុមអាជ្ញាកណ្តាល ត្រូវតំកល់ទុកនូវឯកសារ :

(ក) ភស្តុតាងណាមួយ ដែលបានផ្តល់អោយក្នុងការជំនុំជំរះអាជ្ញាកណ្តាល និង

(ខ) សេចក្តីបង្គាប់អាជ្ញាកណ្តាល ឬ សេចក្តីសំរេច ដែលធ្វើឡើងដោយក្រុមអាជ្ញាកណ្តាល ។

ឯកសារ អាចត្រូវតំកល់ទុក ក្នុងរូបភាពជាកំណត់ហេតុសរសេរ ឬ ក្នុងរូបភាពផ្សេងទៀត រួមទាំងការថតចំលងដោយអេឡិចត្រូនិច ។

## វិធាន ៥ : សេចក្តីបង្គាប់

៥.១ ក្រុមអាជ្ញាកណ្តាល ត្រូវជូនដំណឹងទៅលេខាធិការដ្ឋាន អំពីសេចក្តីបង្គាប់អាជ្ញាកណ្តាលរបស់ខ្លួន ក្នុងរយៈពេល ១៥ថ្ងៃប្រតិទិន ចាប់រាប់ពីថ្ងៃបង្កើតក្រុមអាជ្ញាកណ្តាលដំបូង លើកលែងតែ ភាគីបានព្រមព្រៀងគ្នាផ្សេងពីនេះ ដូចមានចែងក្នុងប្រការ ៣០ នៃប្រកាស និងវិធាន ៨.៩ ខាងលើ ។

៥.២ ក្រុមអាជ្ញាកណ្តាល ត្រូវបង្ហាញសេចក្តីបង្គាប់របស់ខ្លួនជាលាយល័ក្ខអក្សរ ទៅលេខាធិការដ្ឋាន ក្នុងទំរង់គំរូ ដែលផ្តល់អោយ ដោយលេខាធិការដ្ឋាន ។

៥.៣ បន្ទាប់ពីបានទទួលសេចក្តីបង្គាប់ លេខាធិការដ្ឋាន ត្រូវជូនដំណឹងជាបន្ទាន់ទៅភាគី ដោយផ្តល់អោយពួកគេ នូវសេចក្តីបង្គាប់ដែលបានបញ្ជាក់ថាត្រឹមត្រូវចំនួន១ច្បាប់ ។ ការជូនដំណឹងទៅភាគី អាចធ្វើឡើងតាមរយៈបញ្ជូនសេចក្តីបង្គាប់ទៅភាគី តាមរយៈអាស័យដ្ឋានរបស់គេ ដែលពួកគេបានផ្តល់អោយលេខាធិការដ្ឋាន ដោយផ្អែកតាមវិធាន ២.៣ ខាងលើ ឬ តាមរយៈអាស័យដ្ឋាននៃអ្នកតំណាងភាគី ។

## វិធាន ៦ : ឯកសារ និង ការប្រាស្រ័យទាក់ទងផ្សេងៗទៀត ដែលទាក់ទងនឹងដំណើរការអាជ្ញាកណ្តាល

៦.១ ក្នុងគោលបំណងនៃដំណើរការអាជ្ញាកណ្តាល ស្របតាមជំពូក ១២ ផ្នែក ២ នៃច្បាប់ស្តីពីការងារ ឬស្របតាមប្រកាស នៅពេលដែលបុគ្គល ឬ ភាគីណាមួយ ត្រូវប្រគល់ឯកសារ ឬ តំកល់ឯកសារជូនរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា សេវាកម្មដូចនេះ នឹងចាត់ថាបានសំរេចលទ្ធផល ដោយការបញ្ជូនយ៉ាងត្រឹមត្រូវនូវឯកសារទាំងនោះ ទៅលេខាធិការដ្ឋាន ។ វិធាននេះ ក៏អនុវត្តផងដែរ ចំពោះរបាយការណ៍ផ្សះផ្សាមិនសះជា ដូចមានចែងក្នុងមាត្រា ៣០៨ នៃច្បាប់ស្តីពីការងារ និង ចំពោះការជំទាស់ ដូចមានចែងក្នុងប្រការ ៤០ នៃប្រកាស ។

៦.២ ក្នុងគោលបំណងនៃដំណើរការអាជ្ញាកណ្តាល ស្របតាមជំពូក ១២ ផ្នែក ២ នៃច្បាប់ស្តីពីការងារ ឬស្របតាមប្រកាស នៅពេលដែលបុគ្គល ឬ ភាគីណាមួយ ត្រូវប្រគល់ ឬ ជូនឯកសារណាមួយ ភាគីនោះត្រូវតែអាចបង្ហាញជាភស្តុតាងថា សេវាកម្ម និង ការបញ្ជូននោះបានកើតឡើង ។ វិធីដែលអាចទទួលយកបាន សម្រាប់សេវាកម្ម ឬ ការបញ្ជូនឯកសារនេះ រួមមាន :

(ក) ការបញ្ជូនឯកសារតាមទូរសារ និង ការរក្សាទុកកន្ទុយសន្លឹក

(ខ) បញ្ជូនឯកសារតាមអ្នករត់សារ ហើយមានបង្កាន់ដៃបញ្ជាក់ថាបានទទួល និង

(គ) ប្រគល់ដល់ដៃ ហើយមានបង្កាន់ដៃបញ្ជាក់ថាបានទទួល ។

វិធានក៏អនុវត្តចំពោះការជំទាស់សេចក្តីបង្គាប់ផងដែរ ដូចមានចែងក្នុងប្រការ ៤០ នៃប្រកាស ។

៦.៣ ដោយសារពេលវេលា ជាកត្តាសំខាន់ ក្នុងការអនុវត្តដំណើរការក្រុមប្រឹក្សាអាជ្ញាកណ្តាល ដូច្នេះការទាក់ទងគ្នា ដោយប្រើទូរស័ព្ទត្រូវបានគេលើកទឹកចិត្ត ក្នុងចំណោមភាគីដែលពាក់ព័ន្ធ លើកលែងតែច្បាប់ស្តីពីការងារ ប្រកាស ឬ វិធាននេះ តម្រូវឱ្យមានការទាក់ទងគ្នាជាលាយលក្ខណ៍អក្សរជាក់លាក់ ។ ក្នុងករណីណាក៏ដោយភស្តុតាងបញ្ជាក់អំពីការទាក់ទងគ្នានេះ អាចតម្រូវឱ្យមាន ។

៦.៤ រាល់ល័ក្ខខ័ណ្ឌតម្រូវទាំងឡាយក្នុងប្រកាស ឬ ក្នុងវិធាននេះ ដែលលេខាធិការដ្ឋាន ឬអាជ្ញាកណ្តាល ទាក់ទងជាមួយនឹងភាគីណាមួយ នឹងយកជាការបាន បើសិនជាមានការទាក់ទងជាមួយតំណាងពេញសិទ្ធិរបស់ភាគីនោះ ។

**វិធាន ៧ : ការធ្វើវិសោធនកម្មលើវិធាននៃនីតិវិធីនេះ**

៧.១ នៅពេលមានការតំរូវអោយធ្វើវិសោធនកម្មលើវិធាននៃនីតិវិធីនេះ រដ្ឋមន្ត្រីនៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា អាចធ្វើវិសោធនកម្មដូចនេះ បន្ទាប់ពីមានការពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាអាជ្ញាកណ្តាល ។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួង សង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ**
**និងយុវនីតិសម្បទា**
លេខៈ ៣៣៩ សកបយ

ភ្នំពេញ, ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០០២

# ប្រកាស
## ស្តីពី
## ការបង្កើតគណៈកម្មការគ្រប់គ្រងពលករបរទេស

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាស ឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
- បានឃើញអនុក្រឹត្យ លេខ ៨៧អនក្រ/បក ចុះថ្ងៃ ទី ០៤ ខែ តុលា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
- បានឃើញ លិខិតលេខ ១១៦៦ សជណ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០០២ របស់ទីស្តីការគណៈរដ្ឋមន្ត្រី

## សំរេច

**ប្រការ ១:** បង្កើតគណៈកម្មការគ្រប់គ្រងពលករបរទេស ជាភាសាអង់គ្លេសហៅថា Foreign Workers Administering Committee "FWAC" ស្ថិតនៅក្នុងអគ្គនាយកដ្ឋានការងារ និងបណ្តុះបណ្តាល

វិជ្ជាជីវៈ នៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈនិងយុវនីតិសម្បទា ដើម្បីគ្រប់គ្រងពលករបរទេសទាំងអស់ដែលចូលមកប្រកបមុខរបរនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលស្ថិតនៅក្រោមបទបញ្ញត្តិនៃច្បាប់ ស្តីពីការងារ ។

**ប្រការ ២ៈ** គណៈកម្មការគ្រប់គ្រងពលករបរទេស មានភារកិច្ចដូចតទៅៈ

១- រៀបចំបែបបទនានា ស្តីពីការស្នើសុំយកពលករបរទេសមកប្រកបមុខរបរនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ បែបបទនេះត្រូវដាក់ជូនទៅនាយកដ្ឋានជំនាញរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ដើម្បីពិនិត្យ និងសំរេច ស្របទៅតាមករណីជាក់ស្តែងនីមួយៗ ។

២- រៀបចំបែបបទជាផ្លូវការស្តីពីការដាក់អោយពលករបរទេសធ្វើការនៅក្នុងសហគ្រាសគ្រឹះស្ថាននានាក្រោយពេលដែលសហគ្រាស គ្រឹះស្ថានទាំងនោះទទួលបានការយល់ព្រមជាគោលការណ៍ពីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។

៣- សហការជាមួយក្រសួងមហាផ្ទៃ តំណាងការងារទូតប្រទេសដើមរបស់ពលករបរទេស និងសមាគមនិយោជក និងនិយោជក ដើម្បីដោះស្រាយរាល់ការងារដែលពាក់ព័ន្ធជាមួយពលករបរទេស ។

៤- សហការជាមួយនាយកដ្ឋានជំនាញ ដើម្បីពង្រឹងការងារអធិការកិច្ចពលករបរទេស និងទំនាក់ទំនង វិជ្ជាជីវៈរវាងពលករបរទេស និងនិយោជក ។

**ប្រការ ៣ៈ** បង្កើតលេខាធិការដ្ឋានមួយនៅក្នុងនាយកដ្ឋានមុខរបរ និងហត្ថពលកម្មជាជំនួយការរបស់គណៈកម្មការគ្រប់គ្រងពលករបរទេស ដែលមានមន្ត្រីជំនាញបំរើការមកពីនាយកដ្ឋានមុខរបរ និងហត្ថពលកម្មនាយកដ្ឋានពេទ្យការងារ និងនាយកដ្ឋានបច្ចេកទេសវិជ្ជាជីវៈ និងទីផ្សារការងារ ។

សមាសភាពមន្ត្រីនៃលេខាធិការដ្ឋានមានៈ

| | | | |
|---|---|---|---|
| ១-លោក ហ៊ូ វុឌ្ឍី | អគ្គនាយករងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ប្រធាន |
| ២-លោក គ្រួច សុផារី | អគ្គនាយករងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | អនុប្រធាន |
| ៣-លោក សេង សក្ដា | ប្រធាននាយកដ្ឋានមុខរបរ និងហត្ថពលកម្ម | អនុប្រធាន |
| ៤-លោក ឃួន ឡានិច | អនុប្រធាននាយកដ្ឋានមុខរបរ និងហត្ថពលកម្ម | សមាជិកអចិន្ត្រៃយ៍ |
| ៥-លោក ថេត សំអឿន | អនុប្រធានការិយាល័យស្ថិតិមុខរបរ និងហត្ថពលកម្ម | សមាជិក |

៦-លោក ឃុន ពិសិដ្ឋារ៉ា មន្ត្រីការិយាល័យត្រួតពិនិត្យជនបរទេស សមាជិក

៧-លោក ជូរ រតនះ មន្ត្រីនាយកដ្ឋានពេទ្យការងារ សមាជិក

៨-លោក ជួន ឃុន មន្ត្រីនាយកដ្ឋានបច្ចេកទេសវិជ្ជាជីវៈ និងទីផ្សារការងារ សមាជិក

មន្ត្រីដែលត្រូវបានចាត់តាំងឱ្យទទួលភារកិច្ចនៅក្នុងលេខាធិការដ្ឋាននៃគណៈកម្មការគ្រប់គ្រងពលករបរទេសត្រូវបានរក្សាក្របខ័ណ្ឌ បៀវត្ស ការតំឡើងឋានៈ និងការលើកសរសើរនៅអង្គភាពដើម ។

**ប្រការ ៤៖** ខុទ្ទការល័យរដ្ឋមន្ត្រី អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នាយកដ្ឋានមុខរបរ និងហត្ថពលកម្ម នាយកដ្ឋានបច្ចេក ទេសវិជ្ជាជីវៈ និងទីផ្សារការងារ នាយកដ្ឋានពេទ្យការងារ និងមន្ត្រីដែលទទួលភារកិច្ចនៅក្នុងប្រការ ៣ ត្រូវអនុវត្តប្រកាសនេះប្រកបដោយប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ប្រការ ៥៖** ត្រូវចាត់ទុកជានិរាករណ៍នូវប្រកាសលេខ ២៨៤ សកបយ ចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ ២០០២ របស់ក្រសួង សង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ស្តីពីការបង្កើតអង្គភាពពលករបរទេស ។

**ប្រការ ៦៖** រាល់បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

រដ្ឋមន្ត្រី

អ៊ិត សំហេង

**ចម្លងជូន**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
-សមាគមនិយោជក នៃព្រះរាជាណាចក្រកម្ពុជា "ដើម្បីជូនជ្រាប"
-ដូចប្រការ ៣ និងប្រការ ៥ "ដើម្បីអនុវត្ត"
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ